# ព្រឹទ្ធសភា

# SENATE MAGAZINE

## ទស្សនាវដ្តីប្រចាំខែកញ្ញា



លេខ ២៧៥ ឆ្នាំទី២៣ ពុទ្ធសករាជ ២៥៦៧ គ្រិស្តសករាជ ២០២៣

Issue 275 Volume 23 Before Christ 2567 Common Era 2023

# មាតិកា

## សកម្មភាពថ្នាក់ដឹកនាំ




- សម្តេចប្រមុខរដ្ឋស្តីទីទទួលជួបពិភាក្សាការងារជាមួយប្រធានរដ្ឋសភាកូរ៉េ ................ ១
- សម្តេចប្រមុខរដ្ឋស្តីទីអនុញ្ញាតឱ្យឯកអគ្គរដ្ឋទូតតែងតាំងថ្មី នៃប្រទេសអ៊ុយក្រែន ចូលជួបជូនសារតាំង និងសម្តែងការគួរសម ........................................................ ៤
- សម្តេចប្រមុខរដ្ឋស្តីទីទទួលសារតាំងពីឯកអគ្គរដ្ឋទូតតែងតាំងថ្មី នៃសាធារណរដ្ឋអាស៊ែបៃហ្សង់ .................................................................................................. ៦
- ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ឹម កា ប្រធានស្តីទីព្រឹទ្ធសភា ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា .... ៨
- ព្រឹទ្ធសភាបើកសម័យប្រជុំវិសាមញ្ញ ដើម្បីពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ បង្កើតក្រសួង ស្ថាប័នចំនួន២ .................................................................................................. ៩


## សកម្មភាពគណៈកម្មការ




- គណៈប្រតិភូគណៈកម្មការទី៥ព្រឹទ្ធសភា ជួបពិភាក្សាការងារជាមួយអាជ្ញាធរ នៅច្រកទ្វារព្រំដែនអន្តរជាតិត្រពាំងក្រៀល ........................................................១១
- គណៈកម្មការទី៧ព្រឹទ្ធសភា ចុះឈ្វេងយល់អំពីវិស័យពាក់ព័ន្ធជាសមត្ថកិច្ច របស់ខ្លួន នៅខេត្តក្រចេះ និងខេត្តត្បូងឃ្មុំ ........................................................១៣
- ក្រុមសមាជិកាព្រឹទ្ធសភា អញ្ជើញជួបសំណេះសំណាល សួរសុខទុក្ខយុទ្ធជនពិការ និងអតីតយុទ្ធជន ខេត្តកំពង់ឆ្នាំង .................................................................................................. ១៥
- គណៈកម្មការទាំង១០ព្រឹទ្ធសភាចូលរួមកិច្ចប្រជុំនានា ...................................................... ១៧
- ការងារទទួលពាក្យបណ្តឹង .................................................................................................១៩
- សមាជិក សមាជិកាព្រឹទ្ធសភាបំពេញការងារនៅតាមបណ្តាភូមិភាគទាំង៨..................................២០
- សមាជិក សមាជិកាព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ ..............................................................២៧


## សកម្មភាពអគ្គលេខាធិការដ្ឋាន




- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែសីហា និងកំណត់ទិសដៅការងារខែកញ្ញា ឆ្នាំ២០២៣ ................................................ ២៩
- ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភាអញ្ជើញចូលរួមមហាសន្និបាតសមាគម អគ្គលេខាធិការសភាប្រើភាសាបារាំង ........................................................ ៣០
- ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ ...................................... ៣១



**អ្នកគ្រប់គ្រងទូទៅ**
ឯកឧត្តម អ៊ុំ សារឹទ្ធ

**អ្នកសម្រួលខ្លឹមសារ និងអក្ខរាវិរុទ្ធ**
ឯកឧត្តម កែវ ចាន់ណា
ឯកឧត្តម សុខ រិទ្ធី
ឯកឧត្តម គឹម ពិសិដ្ឋ
ឯកឧត្តម ជួន ណា
លោក ជួន សុខធី
លោក ទេព មករា
លោក កុក វ៉េ

**អ្នកគ្រប់គ្រងផ្ទាល់**
លោក ទេព មករា

**ក្រុមអ្នកយកព័ត៌មាន**
ការិយាល័យព័ត៌មាន

**ការីកុំព្យូទ័រ**
លោក ជុំ ច័ន្ទរតនា
លោក ធុន គីមធី
លោក គិន ប៉ាត់ថាមីរ


*ក្របមុខ ៖ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ថតរូបអនុស្សាវរីយ៍ជាមួយឯកឧត្តម គីម ជីនផ្យូ (Kim Jinpyo) ប្រធានរដ្ឋសភា នៃសាធារណរដ្ឋកូរ៉េ។*

*ក្របក្រោយ ៖ ទិដ្ឋភាពក្នុងសម័យប្រជុំវិសាមញ្ញព្រឹទ្ធសភា នីតិកាលទី៥៕*


**អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា**
**វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា**
**ទូរស័ព្ទ: (855) 23 211441, 211442, 211443, ទូរសារ: (855) 23 211446**
**E-mail : oumsarith.sgsenate@gmail.com**
**Website: www.senate.gov.kh**
**www.elibrary.senate.gov.kh**
**Facebook: www.facebook.com/senateofcambodia**

# សម្តេចប្រមុខរដ្ឋស្តីទីទទួលជួបពិភាក្សាការងារជាមួយប្រធានរដ្ឋសភាកូរ៉េ



*ឯកឧត្តម គីម ជីនផ្យូ និងសម្តេចវិបុលសេនាភក្តី សាយ ឈុំ*

នាព្រឹកថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២៣ វេលាម៉ោង៩:០០ នាទី នៅវិមានព្រឹទ្ធសភា សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា បានទទួលជួបពិភាក្សាការងារជាមួយនឹងឯកឧត្តម **គីម ជីនផ្យូ** (Kim-Jinpyo) ប្រធានរដ្ឋសភា នៃសាធារណរដ្ឋកូរ៉េ ក្នុងឱកាសអញ្ជើញមកបំពេញទស្សនកិច្ចជាផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា។

ក្នុងព្រះបរមនាម ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងក្នុងនាមសម្តេចផ្ទាល់សម្តេចប្រមុខរដ្ឋស្តីទី បានសម្តែងនូវសេចក្តីសោមនស្សរីករាយ និងស្វាគមន៍ដ៏កក់ក្តៅចំពោះឯកឧត្តម **គីម ជីនផ្យូ** ប្រធានរដ្ឋសភា នៃសាធារណរដ្ឋកូរ៉េ ដែលបានដឹកនាំគណៈប្រតិភូមកបំពេញទស្សនកិច្ចជាផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា។ តាមរយៈដំណើរទស្សនកិច្ចជាផ្លូវការរបស់ឯកឧត្តម **គីម ជីនផ្យូ** ពិតជាបានឆ្លុះបញ្ចាំងពីការយកចិត្តទុកដាក់ពង្រឹងពង្រីកចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងប្រទេស និងប្រជាជនទាំងពីរដែលមានផលប្រយោជន៍ទៅវិញទៅមកសម្រាប់ប្រជាជន និងប្រទេសទាំងពីរទាំងពេលបច្ចុប្បន្ន និងពេលអនាគត។

ក្នុងឱកាសនោះ ឯកឧត្តម **គីម ជីនផ្យូ** បានថ្លែងអំណរគុណសម្តេចប្រមុខរដ្ឋស្តីទី ដែលបានទទួលជួបគណៈប្រតិភូ និងបានសម្តែងនូវការអបអរសាទរ ចំពោះការបង្កើតរាជរដ្ឋាភិបាលថ្មីរបស់កម្ពុជា កាលពីថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣កន្លងទៅ។

ឯកឧត្តមប្រធានរដ្ឋសភាកូរ៉េ បានលើកឡើងអំពីទស្សនកិច្ចរបស់ឯកឧត្តមនៅកម្ពុជាក្នុងឆ្នាំ២០០០ ក្នុងនាមជាអនុរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ បានធ្វើការជាមួយនឹងសម្តេចតេជោ លើការចុះហត្ថលេខាលើគម្រោង ODA។ ២៣ឆ្នាំក្រោយ ឯកឧត្តមទើបបានធ្វើទស្សនកិច្ចនៅកម្ពុជាសាជាថ្មីក្នុងនាមជាប្រធានរដ្ឋសភាកូរ៉េ។

ឯកឧត្តមប្រធានរដ្ឋសភាកូរ៉េ បានវាយតម្លៃខ្ពស់ចំពោះការអភិវឌ្ឍយ៉ាងឆាប់រហ័សរបស់កម្ពុជា ទាំងផ្នែកសេដ្ឋកិច្ច នយោបាយ និងសង្គម។ ឯកឧត្តមមានជំនឿជឿជាក់ថា កម្ពុជានឹងសម្រេចបានការរីកចម្រើនសេដ្ឋកិច្ចកាន់តែរឹងមាំ និងជោគជ័យគ្រប់ផ្នែកថែមទៀត ដូចដែលបានសម្រេចកាលពីពេលកន្លងមកក្រោមការដឹកនាំរបស់សម្តេចតេជោ ជាមួយនឹងការគាំទ្រពីអង្គការនីតិប្បញ្ញត្តិ នៃប្រទេសទាំងពីរ។ ជាមួយគ្នានោះ ឯកឧត្តមជឿជាក់ថា ថ្នាក់ដឹកនាំវ័យក្មេងរបស់កម្ពុជានាពេលបច្ចុប្បន្ននឹងនាំកម្ពុជាឱ្យសម្រេចបាននូវគោលដៅប្រែក្លាយកម្ពុជាទៅជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងប្រទេសដែលមានប្រាក់ចំណូលកម្រិតខ្ពស់នៅឆ្នាំ២០៥០។

ឯកឧត្តមប្រធានរដ្ឋសភាកូរ៉េ បានបញ្ជាក់អំពីបំណងរបស់រដ្ឋាភិបាល និងសភាកូរ៉េ ក្នុងការបន្តពង្រឹងទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការល្អជាមួយនឹងកម្ពុជាកាន់តែរឹងមាំ ដោយចាត់ទុកកម្ពុជាជាដៃគូសំខាន់ក្នុងក្របខ័ណ្ឌអាស៊ាន-កូរ៉េ និងជាប្រទេសដៃគូ ODA ដ៏សំខាន់។ ដើម្បីសម្រេចគោលដៅទាំងនេះ ប្រទេសទាំងពីរត្រូវតែលើកកម្ពស់ទំនាក់ទំនង និងកិច្ចប្រតិបត្តិការឱ្យកាន់តែស៊ីជម្រៅ តាមរយៈការផ្លាស់ប្តូរដំណើរទស្សនកិច្ចរបស់ថ្នាក់ដឹកនាំ នៃប្រទេសទាំងពីរ។

ជាមួយគ្នានោះ ឯកឧត្តមប្រធានរដ្ឋសភាកូរ៉េបានថ្លែងអំណរគុណកម្ពុជាដែលបានគាំទ្រសាធារណរដ្ឋកូរ៉េ ធ្វើជាម្ចាស់ផ្ទះរៀបចំពិព័រណ៍ពិភពលោកនៅឆ្នាំ២០៣០ ខាងមុខ

នៅទីក្រុង Busan។ ប្រទេសកម្ពុជាជាប្រទេសទី១ក្នុងតំបន់អាស៊ាន ដែលបានផ្តល់ការគាំទ្រដល់សាធារណរដ្ឋកូរ៉េ។ ហើយការបោះឆ្នោតសម្រេច នៃការធ្វើជាម្ចាស់ផ្ទះពិព័រណ៍ពិភពលោក នឹងប្រព្រឹត្តទៅនៅសប្តាហ៍ទី១ ខែវិច្ឆិកា ឆ្នាំនេះ។

ឯកឧត្តមប្រធានរដ្ឋសភាកូរ៉េបានបញ្ជាក់ថា នាពេលថ្មីៗនេះ ការវាយតម្លៃលើគម្រោង នៃការសាងសង់ស្ពានមិត្តភាពកម្ពុជា-កូរ៉េទើបបានបញ្ចប់ ហើយការសាងសង់នឹងចាប់ផ្តើមនាពេលឆាប់ៗខាងមុខ។ ឯកឧត្តមសង្ឃឹមថា ស្ពាននេះនឹងជួយរួមចំណែកដល់ការអភិវឌ្ឍរបស់កម្ពុជា និងជានិមិត្តរូប នៃមិត្តភាពកម្ពុជា-កូរ៉េ។ ប្រទេសទាំងពីរនឹងបន្តពង្រឹងកិច្ចសហប្រតិបត្តិការឱ្យកាន់តែរឹងមាំ ដើម្បីទាក់ទាញក្រុមហ៊ុនកូរ៉េមកវិនិយោគនៅកម្ពុជា និងបន្តពង្រីកលើវិស័យនានាបន្ថែមទៀត ហើយកិច្ចសហប្រតិបត្តិការដ៏រឹងមាំរវាងប្រទេសទាំងពីរនឹងរួមចំណែកដល់សន្តិភាព ស្ថិរភាព និងអភិវឌ្ឍន៍នៅតំបន់អាស៊ាន ក៏ដូចជាតំបន់មេគង្គផងដែរ។

សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រមុខរដ្ឋស្តីទី បានសម្តែងនូវការពេញចិត្តដោយមើលឃើញទំនាក់ទំនងរវាងប្រទេសទាំងពីរបន្តរីកចម្រើនជាបន្តបន្ទាប់។ ការរីកចម្រើននេះ ស្តែងឡើងតាមរយៈការផ្លាស់ប្តូររវាងប្រជាជន និងប្រជាជន ការគាំទ្រគ្នាទៅវិញទៅមកលើកិច្ចសហប្រតិបត្តិការអន្តរជាតិ សំដៅរួមចំណែកកសាងសន្តិភាព សន្តិសុខ ស្ថិរភាព ការអភិវឌ្ឍក្នុងតំបន់ និងសកលលោក។

ក្នុងនាមប្រជាជនកម្ពុជា សម្តេចប្រមុខរដ្ឋស្តីទីបានថ្លែងអំណរគុណរដ្ឋាភិបាល និងប្រជាជនកូរ៉េ ដែលបានផ្តល់ជំនួយអភិវឌ្ឍផ្លូវការ ហិរញ្ញប្បទានឥតសំណង ហិរញ្ញប្បទានសម្បទាន ចាប់តាំងពីឆ្នាំ១៩៩៧ ដែលជាការកត់សម្គាល់ក្រោមគោលនយោបាយភាគខាងត្បូងថ្មីបូក (New Southern Policy Plus) កម្ពុជាជាប្រទេសអាទិភាពសម្រាប់ផ្តល់ជំនួយអភិវឌ្ឍផ្លូវការ។ នៅឆ្នាំ២០២២ កម្ពុជាជាប្រទេសទទួលបានជំនួយច្រើនជាងគេក្នុងចំណោមប្រទេសដៃគូអភិវឌ្ឍន៍របស់កូរ៉េក្នុងទឹកប្រាក់ចំនួន១៥០លានដុល្លារ-អាមេរិក។

សម្តេចប្រមុខរដ្ឋស្តីទី បានបញ្ជាក់ថា វំហូរវិនិយោគដោយផ្ទាល់ពីសាធារណរដ្ឋកូរ៉េ និងទេសចរកូរ៉េ បានដើរតួនាទីដ៏សំខាន់ក្នុងការរួមចំណែកដល់ការអភិវឌ្ឍសង្គមសេដ្ឋកិច្ចកម្ពុជា កាត់បន្ថយភាពក្រីក្រ លើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាកាន់តែល្អប្រសើរ។ ការរីកចម្រើនផ្នែកសង្គម-សេដ្ឋកិច្ចកម្ពុជា ទាំងពេលបច្ចុប្បន្ន និងពេលអនាគត គឺមិនអាចកាត់ផ្តាច់បានពីការគាំទ្ររបស់សាធារណរដ្ឋកូរ៉េបានឡើយ។ ឆ្នាំ២០២៣នេះ រដ្ឋាភិបាលកូរ៉េគ្រោងនឹងផ្តល់ជំនួយឥតសំណងប្រមាណ ២៣,២២លានដុល្លារអាមេរិក



*ទិដ្ឋភាពក្នុងពិធីជំនួបសវនាការ*

សម្រាប់ការអនុវត្តគម្រោងផ្សេងៗ ក្រោមក្របខ័ណ្ឌ KOICA ក្នុងវិស័យសុខាភិបាល អប់រំ វប្បធម៌ អភិវឌ្ឍជនបទ កសិកម្ម ការបោសសម្អាតមីន និងបរិស្ថាន។ ជំនួយទាំងអស់នេះជាកាយវិការដ៏សប្បុរសរបស់រដ្ឋាភិបាលកូរ៉េដែលបានរួមចំណែកជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីអភិវឌ្ឍលើវិស័យអាទិភាពជាច្រើន ពិសេសការបោសសម្អាតមីន ដែលជាការគាំទ្រដល់គោលដៅកម្ពុជាគ្មានមីននៅឆ្នាំ២០២៥។

សម្ដេចប្រមុខរដ្ឋស្ដីទី បានអរគុណរដ្ឋាភិបាលកូរ៉េ ដែលបានផ្ដល់ជំនួយជាថវិកា និងសម្ភារៈសុខាភិបាល ដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងកាលៈទេសៈលំបាក ដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩។ ជាមួយគ្នានោះ សម្ដេចបានអរគុណដល់រដ្ឋាភិបាលកូរ៉េ ដែលបានជួយយកចិត្តទុកដាក់ចំពោះពលករកម្ពុជា និងជួយសម្រួលនីតិវិធីការងារក្នុងបរិបទជំងឺកូវីដ-១៩ និងផ្ដល់វ៉ាក់សាំងដល់ពលករកម្ពុជាដែលកំពុងបំពេញការងារនៅកូរ៉េនាពេលកន្លងទៅ និងបានយកចិត្តទុកដាក់ខ្ពស់បង្កើនកូតាពលករកម្ពុជាប្រមាណ ៤០% បន្ថែមទៀតនៅឆ្នាំ២០២៣។ ពលករកម្ពុជាធ្វើការនៅកូរ៉េបានរួមចំណែកយ៉ាងសំខាន់ដល់ការលើកកម្ពស់ជីវភាពគ្រួសាររបស់គេ លើកកម្ពស់កំណើនសេដ្ឋកិច្ចកម្ពុជា និងបានរួមចំណែកក្នុងការផ្លាស់ប្ដូរប្រពៃណី វប្បធម៌ តាមរយៈការរៀបអាពាហ៍ពិពាហ៍ជាមួយនឹងប្រជាជនកូរ៉េ។

សម្ដេចប្រមុខរដ្ឋស្ដីទី បានសម្ដែងនូវការអបអរសាទរចំពោះការសម្រេចនូវសមិទ្ធផលសង្គម-សេដ្ឋកិច្ចដ៏ធំធេងរបស់សាធារណរដ្ឋកូរ៉េ ក្រោមការដឹកនាំរបស់ឯកឧត្ដមប្រធានាធិបតី និងថ្នាក់ដឹកនាំកូរ៉េ នឹងបន្តសម្រេចបានជោគជ័យក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចប្រកបដោយវិបុលភាព វឌ្ឍនភាព និងសុភមង្គល។ កម្ពុជាចាត់ទុកការរីកចម្រើនរបស់សាធារណរដ្ឋកូរ៉េ ជាការរីកចម្រើនរបស់កម្ពុជា និងជាការរីកចម្រើនរួមរបស់តំបន់ និងបានរួមចំណែកយ៉ាងសំខាន់ដល់ការនាំមកនូវសន្តិភាព សន្តិសុខ ស្ថិរភាពក្នុងតំបន់ និងអន្តរជាតិ។

ក្នុងឱកាសដ៏ល្អប្រពៃនោះ សម្ដេចប្រមុខរដ្ឋស្ដីទីបានពាំនាំនូវព្រះរាជបណ្ដាំសួរសុខទុក្ខដោយសេចក្ដីស្រឡាញ់រាប់អាន នឹករលឹកដ៏ជ្រាលជ្រៅបំផុតពីព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជូនឯកឧត្ដមប្រធានរដ្ឋសភា និងតាមរយៈឯកឧត្ដម ពាំនាំនូវព្រះរាជបណ្ដាំសួរសុខទុក្ខជូនឯកឧត្ដម **យូន ស៊ុកយ៉ុល** ប្រធានាធិបតី នៃសាធារណរដ្ឋកូរ៉េ។ សម្ដេចប្រមុខរដ្ឋស្ដីទីបានប្រសិទ្ធពរជូនឯកឧត្ដម **គីម ជីនផ្យូ** និងគណៈប្រតិភូសូមមានសុខភាពល្អ និងទទួលបានជោគជ័យក្នុងការស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា៕

(អត្ថបទ៖ នុត សច្ចៈ រូបភាព៖ គង់ យ៉ារីន)



*សម្ដេចប្រមុខរដ្ឋស្ដីទី ថតរូបអនុស្សាវរីយ៍ជាមួយគណៈប្រតិភូរដ្ឋសភាកូរ៉េ*

# សម្តេចប្រមុខរដ្ឋស្តីទីអនុញ្ញាតឱ្យឯកអគ្គរដ្ឋទូតតែងតាំងថ្មី នៃប្រទេសអ៊ុយក្រែន ចូលជួបជូនសារតាំង និងសម្តែងការគួរសម





*ឯកឧត្តម Gaman Oleksandr ប្រគល់សារតាំងជូនសម្តេចប្រមុខរដ្ឋស្តីទី និងសម្តែងការគួរសម*

នាព្រឹកថ្ងៃពុធ ទី១៣ ខែកញ្ញា ឆ្នាំ២០២៣ វេលាម៉ោង ៩:០០នាទី សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឱ្យឯកឧត្តម Gaman Oleksandr ឯកអគ្គរដ្ឋទូតតែងតាំងថ្មី នៃប្រទេសអ៊ុយក្រែន ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបជូនសារតាំង និងសម្តែងការគួរសម នៅវិមានព្រឹទ្ធសភា។

ក្នុងព្រះបរមនាមព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងនាមព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាលកម្ពុជា និងក្នុងនាមសម្តេចផ្ទាល់ សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** បានសម្តែងអំណរសាទរស្វាគមន៍ចំពោះឯកឧត្តម Gaman Oleksandr ដែលត្រូវបានឯកឧត្តមប្រធានាធិបតី នៃប្រទេសអ៊ុយក្រែន តែងតាំងជាឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃប្រទេសអ៊ុយក្រែន ប្រចាំព្រះរាជាណាចក្រកម្ពុជា។

ក្នុងឱកាសនោះ ឯកឧត្តម Gaman Oleksandr បានថ្លែងអំណរគុណចំពោះសម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រមុខរដ្ឋស្តីទី ដែលបានចំណាយពេលវេលាដ៏មានតម្លៃ អនុញ្ញាតឱ្យឯកឧត្តមចូលជួបជូនសារតាំង និងសម្តែងការគួរសម។ ជាមួយគ្នានោះ ឯកឧត្តមឯកអគ្គរដ្ឋទូត បាននាំនាំនូវការផ្តាំផ្ញើសួរសុខទុក្ខប្រកបដោយក្តីនឹករលឹកពីឯកឧត្តមប្រធានាធិបតី នៃប្រទេសអ៊ុយក្រែន ថ្វាយព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងជូនចំពោះថ្នាក់ដឹកនាំកំពូល នៃព្រះរាជាណាចក្រកម្ពុជាផងដែរ។

ឯកឧត្តមបានសម្តែងនូវការពេញចិត្ត និងវាយតម្លៃខ្ពស់ចំពោះទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការដ៏ល្អប្រពៃរវាងប្រទេសទាំងពីរ។ តាមរយៈបេសកកម្មការទូតរបស់ឯកឧត្តមនៅព្រះរាជាណាចក្រកម្ពុជា ឯកឧត្តមនឹងខិតខំរួមចំណែកពង្រឹងពង្រីកទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការដ៏ល្អប្រពៃរវាងរដ្ឋាភិបាល ប្រជាជន និងប្រទេសទាំងពីរឱ្យកាន់តែល្អប្រសើរថែមទៀត។

សម្តេចប្រមុខរដ្ឋស្តីទីបានកត់សម្គាល់ដោយសេចក្តីរីករាយចំពោះទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការដ៏ល្អរវាងប្រទេសទាំងពីរ។ សម្តេចមានជំនឿជឿជាក់ថា ក្នុងឋានៈឯកឧត្តមជាឯកអគ្គរដ្ឋទូត នៃប្រទេសអ៊ុយក្រែនប្រចាំព្រះរាជាណាចក្រកម្ពុជា ឯកឧត្តមនឹងបន្តខិតខំពង្រឹងពង្រីកចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យ



ទិដ្ឋភាពក្នុងជំនួបសម្ដែងការគួរសម

រវាងប្រទេស និងប្រជាជនទាំងពីរឱ្យកាន់តែប្រសើរឡើងថែមទៀត។

សម្ដេចប្រមុខរដ្ឋស្ដីទីបានបញ្ជាក់ថា ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល ក្រសួង ស្ថាប័នជាតិ នៃព្រះរាជាណាចក្រកម្ពុជាត្រៀមខ្លួនជានិច្ច ដើម្បីធ្វើកិច្ចសហប្រតិបត្តិការដ៏ជិតស្និទ្ធជាមួយនឹងឯកឧត្តមឯកអគ្គរដ្ឋទូត ដើម្បីលើកកម្ពស់ទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការ ដើម្បីនាំមកនូវផលប្រយោជន៍ដ៏ធំធេងទៅវិញទៅមកសម្រាប់ប្រជាជន និងប្រទេសទាំងពីរ។

តាមរយៈឯកឧត្តមឯកអគ្គរដ្ឋទូត សម្ដេចប្រមុខរដ្ឋស្ដីទី បានពាំនាំនូវព្រះរាជបណ្ដាំសួរសុខទុក្ខ សេចក្ដីនឹករលឹក ពីព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងសម្ដេចព្រះមហាក្សត្រី **នរោត្តម មុនិនាថ សីហនុ** និងថ្នាក់ដឹកនាំកំពូល នៃព្រះរាជាណាចក្រកម្ពុជា ជូនចំពោះឯកឧត្តមប្រធានាធិបតី និងថ្នាក់ដឹកនាំកំពូលគ្រប់លំដាប់ថ្នាក់ នៃប្រទេសអ៊ុយក្រែន។

សម្ដេចប្រមុខរដ្ឋស្ដីទី បានប្រសិទ្ធពរជូនឯកឧត្តមឯកអគ្គរដ្ឋទូត សូមមានសុខភាពល្អ និងទទួលបានជោគជ័យក្នុងបេសកកម្មការទូតដ៏ឧត្តុង្គឧត្តមនេះ៕

(អត្ថបទ៖ នុត សច្ចៈ រូបភាព៖ គង់ យ៉ារីន)



សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ ថតរូបអនុស្សាវរីយ៍ជាមួយនឹងឯកអគ្គរដ្ឋទូត នៃប្រទេសអ៊ុយក្រែន

# សម្តេចប្រមុខរដ្ឋស្តីទីទទួលសារតាំងពីឯកអគ្គរដ្ឋទូតតែងតាំងថ្មី នៃសាធារណរដ្ឋអាស៊ែបៃហ្សង់



*ឯកឧត្តម ស៊ូវគី កាម៉ាល អ៊ូកលូ មេឌីហ្សាដា ប្រគល់សារតាំងជូនសម្តេចប្រមុខរដ្ឋស្តីទី*

នាព្រឹកថ្ងៃសុក្រ ទី១៥ ខែកញ្ញា ឆ្នាំ២០២៣ វេលាម៉ោង ៩:០០នាទី សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឱ្យឯកឧត្តម **ស៊ូវគី កាម៉ាល អ៊ូកលូ មេឌីហ្សាដា** (Shovgi Kamal Oglu Mehdizada) ឯកអគ្គរដ្ឋទូតតែងតាំងថ្មី នៃសាធារណរដ្ឋអាស៊ែបៃហ្សង់ ចូលជួបជូនសារតាំង និងសម្តែងការគួរសម នៅវិមានព្រឹទ្ធសភា។

ក្នុងព្រះបរមនាមព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងនាមព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាលកម្ពុជា និងក្នុងនាមសម្តេចផ្ទាល់ សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** បានសម្តែងអំណរសាទរស្វាគមន៍ចំពោះឯកឧត្តម **ស៊ូវគី កាម៉ាល អ៊ូកលូ មេឌីហ្សាដា** ដែលត្រូវបានឯកឧត្តមប្រធានាធិបតី នៃសាធារណរដ្ឋអាស៊ែបៃហ្សង់ តែងតាំងឯកឧត្តមជាឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋអាស៊ែបៃហ្សង់ ប្រចាំព្រះរាជាណាចក្រកម្ពុជា។

ក្នុងឱកាសនោះ ឯកឧត្តម **ស៊ូវគី កាម៉ាល អ៊ូកលូ មេឌីហ្សាដា** បានថ្លែងអំណរគុណចំពោះសម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រមុខរដ្ឋស្តីទី ដែលបានចំណាយពេលវេលាដ៏មានតម្លៃអនុញ្ញាតឱ្យឯកឧត្តមចូលជួបជូនសារតាំង និងសម្តែងការគួរសម។ ជាមួយគ្នានោះ ឯកឧត្តមឯកអគ្គរដ្ឋទូតបានពាំនាំនូវការផ្តាំផ្ញើសួរសុខទុក្ខប្រកបដោយក្តីនឹករលឹកពីឯកឧត្តមប្រធានាធិបតី នៃសាធារណរដ្ឋអាស៊ែបៃហ្សង់ ថ្វាយព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងជូនចំពោះថ្នាក់ដឹកនាំកំពូល នៃព្រះរាជាណាចក្រកម្ពុជា។

ឯកឧត្តមឯកអគ្គរដ្ឋទូតបានប្តេជ្ញាថា ឯកឧត្តមនឹងខិតខំថែរក្សានូវទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការដ៏ល្អប្រពៃ ដែលមានតាំងពីយូរលង់ណាស់មកហើយ និងជាប្រត្តិសាស្ត្ររវាងប្រទេសកម្ពុជា និងសាធារណរដ្ឋអាស៊ែបៃហ្សង់។ ឯកឧត្តមក៏បានរំលឹកកាលពីសម័យអតីតសហភាពសូវៀត ដែលមាននិស្សិតកម្ពុជាជាច្រើនបានទៅសិក្សា



*ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសម*

នៅសាធារណរដ្ឋអាស៊ែបៃហ្សង់។

ឯកឧត្តមឯកអគ្គរដ្ឋទូតបានសម្តែងនូវការពេញចិត្ត និងវាយតម្លៃខ្ពស់ចំពោះទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការដ៏ល្អប្រពៃរវាងប្រទេសទាំងពីរ។ ជាមួយគ្នានោះ ឯកឧត្តមនឹងខិតខំរួមចំណែកពង្រឹងពង្រីកទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការដ៏ល្អប្រពៃរវាងរដ្ឋាភិបាល ប្រជាជន និងប្រទេសទាំងពីរ ឱ្យកាន់តែល្អប្រសើរ ជាពិសេសពង្រឹង-ពង្រីកលើវិស័យពាណិជ្ជកម្ម នយោបាយរវាងប្រទេសទាំងពីរឱ្យកាន់តែមានកម្រិតខ្ពស់ថែមទៀត។

ក្នុងឱកាសដ៏ល្អប្រពៃនោះ សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រមុខរដ្ឋស្តីទី បានកត់សម្គាល់ដោយសេចក្តីរីករាយចំពោះទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការដ៏ល្អរវាងប្រទេសទាំងពីរ។ សម្តេចមានជំនឿជឿជាក់ថា ក្នុងឋានៈឯកឧត្តម **ស៊ូចគី កាម៉ាល អ៊ូកលូ មេឌីហ្សាដា** ជាឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋអាស៊ែបៃហ្សង់ ប្រចាំព្រះរាជាណាចក្រកម្ពុជា ឯកឧត្តមនឹងបន្តខិតខំពង្រឹងពង្រីកចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យរវាងប្រទេស និងប្រជាជនទាំងពីរឱ្យកាន់តែល្អប្រសើរឡើងថែមទៀត។

សម្តេចប្រមុខរដ្ឋស្តីទីបានបញ្ជាក់ថា ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល ក្រសួង ស្ថាប័នជាតិ នៃព្រះរាជាណាចក្រកម្ពុជាត្រៀមខ្លួនជានិច្ច ដើម្បីធ្វើកិច្ចសហប្រតិបត្តិការដ៏ជិតស្និទ្ធជាមួយនឹងឯកឧត្តមឯកអគ្គរដ្ឋទូត ដើម្បីលើក-កម្ពស់ទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការ ដើម្បីនាំមកនូវផលប្រយោជន៍ដ៏ធំធេងទៅវិញទៅមកសម្រាប់ប្រជាជន និងប្រទេសទាំងពីរ។

តាមរយៈឯកឧត្តមឯកអគ្គរដ្ឋទូត សម្តេចប្រមុខរដ្ឋស្តីទីបានពាំនាំនូវព្រះរាជបណ្តាំសួរសុខទុក្ខ សេចក្តីនឹករលឹកពីព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចព្រះមហាក្សត្រី **នរោត្តម មុនិនាថ សីហនុ** និងថ្នាក់ដឹកនាំកំពូល នៃព្រះរាជាណាចក្រកម្ពុជា ជូនចំពោះឯកឧត្តមប្រធានាធិបតី និងថ្នាក់ដឹកនាំកំពូលគ្រប់លំដាប់ថ្នាក់ នៃសាធារណរដ្ឋអាស៊ែបៃហ្សង់។

សម្តេចប្រមុខរដ្ឋស្តីទី បានប្រសិទ្ធពរជូនឯកឧត្តមឯកអគ្គ-រដ្ឋទូត សូមមានសុខភាពល្អ និងទទួលបានជោគជ័យក្នុងបេសកកម្មការទូតដ៏ឧត្តុង្គឧត្តមនេះ៕

(អត្ថបទ៖ នុត សច្ចៈ រូបភាព៖ គង់ យ៉ារីន)



*សម្តេចប្រមុខរដ្ឋស្តីទី ថតរូបអនុស្សាវរីយ៍ជាមួយនឹងឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋអាស៊ែបៃហ្សង់*

❈នាព្រឹកថ្ងៃចន្ទ ទី២៨ ខែសីហា ឆ្នាំ២០២៣ សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជា-ណាចក្រកម្ពុជា បានអញ្ជើញដង្ហែព្រះរាជដំណើរព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះ-មហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចព្រះមហា-ក្សត្រី **នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ស្តេចយាងចាកចេញពីអាកាសយានដ្ឋានអន្តរជាតិ-ភ្នំពេញ ទៅពិនិត្យព្រះរាជសុខភាព នៅទីក្រុងប៉េកាំង សាធារណរដ្ឋប្រជាមានិតចិន៕



# ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ឹម កា ប្រធានស្ដីទីព្រឹទ្ធសភា ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា



*ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ឹម កា និងឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន*

នាថ្ងៃពុធ ទី២០ ខែកញ្ញា ឆ្នាំ២០២៣ វេលាម៉ោង៨:០០ ព្រឹក គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាបានប្រជុំក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស៊ឹម កា** ប្រធានស្ដីទីព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិនិត្យសម្រេចលើរបៀបវារៈចំនួន៥ រួមមាន៖

១-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការមហាផ្ទៃ ការពារជាតិ ទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា អធិការកិច្ច និងមុខងារសាធារណៈ សុំដាក់សេចក្ដីព្រាងច្បាប់ស្ដីពី ការបង្កើតក្រសួងអធិការកិច្ច ទៅក្នុងរបៀបវារៈសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៤។

២-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការមហាផ្ទៃ ការពារជាតិ ទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា អធិការកិច្ច និងមុខងារសាធារណៈ សុំដាក់សេចក្ដីព្រាងច្បាប់ស្ដីពី ការបង្កើតរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន ទៅក្នុងរបៀបវារៈសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៤។

៣-កំណត់របៀបវារៈ កាលបរិច្ឆេទ និងសមាសភាពលេខាធិការសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៤។

៤-ពិនិត្យ និងសម្រេចលើរបាយការណ៍ស្ដីពី សកម្មភាព និងលទ្ធផលការងាររបស់ព្រឹទ្ធសភានៅចន្លោះសម័យប្រជុំលើកទី១០ និងលើកទី១១ នីតិកាលទី៤។

៥-កំណត់របៀបវារៈ និងកាលបរិច្ឆេទ សមាសភាពលេខាធិការសម័យប្រជុំលើកទី១១ ព្រឹទ្ធសភា នីតិកាលទី៤។

បន្ទាប់ពីបានពិនិត្យ និងពិភាក្សារួចមក គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា បានកំណត់យកថ្ងៃព្រហស្បតិ៍ ទី២១ ខែកញ្ញា ឆ្នាំ២០២៣ វេលាម៉ោង៨:០០នាទី ដើម្បីប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៤ ដោយមានរបៀបវារៈដូចខាងក្រោម៖

១-ពិនិត្យ ហើយឱ្យយោបល់លើសេចក្ដីព្រាងច្បាប់ស្ដីពី ការបង្កើតក្រសួងអធិការកិច្ច។

២-ពិនិត្យ ហើយឱ្យយោបល់លើសេចក្ដីព្រាងច្បាប់ស្ដីពី ការបង្កើតរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន។

(អត្ថបទ៖ នុត សច្ចៈ រូបភាព៖ គង់ យ៉ារីន)





*សមាជិក សមាជិកាគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា*

# ព្រឹទ្ធសភាបើកសម័យប្រជុំវិសាមញ្ញ ដើម្បីពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់បង្កើតក្រសួង ស្ថាប័នចំនួន២




*ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ឹម កា និងឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន*

នាព្រឹកថ្ងៃព្រហស្បតិ៍ ទី២១ ខែកញ្ញា ឆ្នាំ២០២៣ វេលាម៉ោង៨:០០នាទី ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានបើកសម័យប្រជុំវិសាមញ្ញ នីតិកាលទី៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស៊ឹម កា** ប្រធានស្តីទីព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ដោយមានវត្តមានសមាជិកព្រឹទ្ធសភាចូលរួមចំនួន៥៩រូប។

អង្គប្រជុំបានដំណើរការដោយមានរបៀបវារៈចំនួន២ រួមមាន៖

**របៀបវារៈទី១៖ ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការបង្កើតក្រសួងអធិការកិច្ច។**

សេចក្តីព្រាងច្បាប់នេះ គឺជាឧបករណ៍គតិយុត្តមួយឆ្លើយតបនឹងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលអាណត្តិទី៧ និងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ បន្តកែទម្រង់ឱ្យស៊ីជម្រៅទូលំទូលាយ មានភាពស៊ីចង្វាក់គ្នា ដែលនឹងផ្តោតលើការលើកកម្ពស់អភិបាលកិច្ច និងសមត្ថភាពស្ថាប័ន ការបង្កើតបរិយាកាសអំណោយផលសម្រាប់អភិវឌ្ឍសង្គមសេដ្ឋកិច្ច ការអភិវឌ្ឍមូលធនមនុស្ស ការធ្វើពិពិធកម្មសេដ្ឋកិច្ច ការបង្កើនភាពប្រកួតប្រជែង ការអភិវឌ្ឍវិស័យឯកជនដែលប្រកបដោយភាពធន់ ចីរភាព បរិយាបន្ន និងសង្គមឌីជីថលជាដើម។




*ឯកឧត្តម សុខ ឥសាន ឡើងអានរបាយការណ៍*

សេចក្តីព្រាងច្បាប់នេះតាក់តែងឡើងមាន ១០មាត្រា និងត្រូវបានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា អនុម័តយល់ព្រមជាលើកដំបូងចំនួន១១៤សំឡេង នៃចំនួនសមាជិករដ្ឋសភាទាំងមូល កាលពីថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២៣ នាសម័យប្រជុំរដ្ឋសភាលើកទី១ នីតិកាលទី៧។

ក្រោយពីសមាជិកព្រឹទ្ធសភាចំនួន២រូបបានឡើងមានយោបល់ និងលើកជាសំណួររួចមកឯកឧត្តម **ហួត ហាក់** រដ្ឋមន្ត្រីក្រសួងអធិការកិច្ច បានឆ្លើយបំភ្លឺជូនអង្គប្រជុំព្រឹទ្ធសភា។



*ឯកឧត្តម ហួត ហាក់ ឡើងការពារសេចក្តីព្រាងច្បាប់*

អង្គប្រជុំព្រឹទ្ធសភាបានពិនិត្យ ហើយឱ្យយោបល់ឯកភាពទាំងស្រុងលើសេចក្តីព្រាងច្បាប់ទាំងមូលដោយឥតកែប្រែ ចំនួន៥៩សំឡេង នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។

**របៀបវារៈទី២៖ ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការបង្កើតរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន។**

សេចក្តីព្រាងច្បាប់ស្តីពី ការបង្កើតរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន ជំនួសឱ្យអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ធ្វើឡើងក្នុងគោលបំណងបង្កើតឱ្យមានស្ថាប័នថ្មីមួយដែលមានលក្ខណៈអចិន្ត្រៃយ៍ មានរចនាសម្ព័ន្ធគ្រប់គ្រង និងសមត្ថកិច្ចពេញលេញ ព្រមទាំងអាចស្រូបទាញបន្ថែមនូវធនធានមនុស្ស ដែលមានសមត្ថភាពជំនាញពិតប្រាកដទាំងផ្នែកបច្ចេកទេស ផ្នែកច្បាប់ជាតិ ច្បាប់អន្តរ-





ទិដ្ឋភាពក្នុងសម័យប្រជុំវិសាមញ្ញព្រឹទ្ធសភា នីតិកាលទី៤

ជាតិ និងផ្នែកជំនាញពាក់ព័ន្ធផ្សេងទៀតដើម្បីលើកកម្ពស់ប្រសិទ្ធភាព នៃការបន្តបេសកកម្មដ៏ពិសិដ្ឋ ក្នុងការដោះស្រាយបញ្ហាព្រំដែនជាមួយនឹងប្រទេសជិតខាង ការពង្រឹងកិច្ចការពារអធិបតេយ្យ និងបូរណភាពទឹកដី និងការលើកស្ទួយការថែរក្សាសមិទ្ធផលព្រំដែនជាប្រវត្តិសាស្ត្រ ដែលរាជរដ្ឋាភិបាលសម្រេចបាន ឱ្យឋិតថេរ គង់វង្សយូរអង្វែងទុកជាមរតកដ៏ឧត្តុង្គឧត្តមជូនកូនខ្មែរគ្រប់ជំនាន់។

ការបង្កើតរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែននេះ ធ្វើឡើងក្នុងចក្ខុវិស័យដើម្បីឈានទៅកសាងខ្សែបន្ទាត់ព្រំដែនជាមួយនឹងប្រទេសជិតខាង ទាំងព្រំដែនគោក និងព្រំដែនសមុទ្រ ប្រកបដោយភាពពេញលេញ ច្បាស់លាស់ និងស្ថាពរ ជាព្រំដែនមិត្តភាព សន្តិភាព ស្ថិរភាព កិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍ ដោយអនុលោមតាមរដ្ឋធម្មនុញ្ញ ច្បាប់ជាតិ ច្បាប់អន្តរជាតិ និងគោលការណ៍ព្រំដែនមិនកែប្រែ។

សេចក្តីព្រាងច្បាប់នេះតាក់តែងឡើងមាន ៨មាត្រា និងត្រូវបានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា អនុម័តយល់ព្រមជាលើកដំបូងចំនួន១១៤សំឡេង នៃចំនួនសមាជិករដ្ឋសភាទាំងមូល កាលពីថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២៣ នាសម័យប្រជុំរដ្ឋសភាលើកទី១ នីតិកាលទី៧។

ក្រោយពីសមាជិកព្រឹទ្ធសភាចំនួន១រូប បានឡើងមានយោបល់ និងលើកជាសំណួររួចមក ឯកឧត្តម **ឡាំ ជា** រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន បានឆ្លើយបំភ្លឺជូនអង្គប្រជុំព្រឹទ្ធសភា។



ឯកឧត្តម ឡាំ ជា ឡើងការពារសេចក្តីព្រាងច្បាប់

អង្គប្រជុំព្រឹទ្ធសភាបានពិនិត្យ ហើយឱ្យយោបល់ឯកភាពទាំងស្រុងលើសេចក្តីព្រាងច្បាប់ទាំងមូល ដោយឥតកែប្រែ ចំនួន៥៩សំឡេង នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល៕

(អត្ថបទ៖ នុត សច្ចៈ រូបភាព៖ គង់ យ៉ារីន)




សមាជិក សមាជិកាព្រឹទ្ធសភា លើកដៃអនុម័តសេចក្តីព្រាងច្បាប់

# គណៈប្រតិភូគណៈកម្មការទី៥ព្រឹទ្ធសភា ជួបពិភាក្សាការងារជាមួយ អាជ្ញាធរនៅច្រកទ្វារព្រំដែនអន្តរជាតិត្រពាំងក្រៀល





*គណៈប្រតិភូគណៈកម្មការទី៥ព្រឹទ្ធសភា ជួបពិភាក្សាការងារជាមួយអាជ្ញាធរនៅច្រកទ្វារព្រំដែនអន្តរជាតិត្រពាំងក្រៀល*

នាព្រឹកថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២៣ គណៈប្រតិភូគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន នៃព្រឹទ្ធសភា (គណៈកម្មការទី៥) ដឹកនាំដោយលោកជំទាវកិត្តិនីតិកោសលបណ្ឌិត **ទី ប៉ូរ៉ាស៊ី** ប្រធានគណៈកម្មការ បានអញ្ជើញជួបពិភាក្សាការងារជាមួយនឹងអាជ្ញាធរមានសមត្ថកិច្ចកំពុងប្រចាំការនៅច្រកទ្វារព្រំដែនអន្តរជាតិត្រពាំងក្រៀល ខេត្តស្ទឹងត្រែង ដឹកនាំដោយលោកវរសេនីយ៍ឯក **ថន ស៊ីថា** នាយរងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិត្រពាំងក្រៀល នៅទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិត្រពាំងក្រៀល ស្ថិតក្នុងស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង។



*លោកជំទាវកិត្តិនីតិកោសលបណ្ឌិត ទី ប៉ូរ៉ាស៊ី*
*ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា*

បន្ទាប់ពីការស្វាគមន៍របស់លោកវរសេនីយ៍ឯក **ថន ស៊ីថា** នាយរងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិត្រពាំងក្រៀលរួចមក លោកជំទាវកិត្តិនីតិកោសលបណ្ឌិត **ទី ប៉ូរ៉ាស៊ី** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា បានថ្លែងអំណរគុណ និងជម្រាបអំពីគោលបំណងរបស់គណៈប្រតិភូគណៈកម្មការទី៥ព្រឹទ្ធសភា គឺមកឈ្វេងយល់អំពីទិដ្ឋភាព និងដំណើរការនៃច្រកទ្វារព្រំដែនអន្តរជាតិត្រពាំងក្រៀល អំពីការអនុវត្តច្បាប់អន្តោប្រវេសន៍ អំពីការចេញ-ចូលរបស់ភ្ញៀវជាតិ និងអន្តរជាតិ ពិសេសជនបរទេសឆ្លងកាត់ព្រមទាំងសួរសុខទុក្ខដល់អាជ្ញាធរមានសមត្ថកិច្ចកំពុងឈរជើងអនុវត្តភារកិច្ចនៅច្រកទ្វារព្រំដែនអន្តរជាតិត្រពាំងក្រៀលទាំងអស់។

ក្នុងឱកាសនោះ លោកវរសេនីយ៍ឯក **ថន ស៊ីថា** នាយរងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិត្រពាំង-





*អាជ្ញាធរប្រចាំការនៅច្រកទ្វារព្រំដែនអន្តរជាតិត្រពាំងក្រៀល និងគណៈប្រតិភូគណៈកម្មការទី៥ព្រឹទ្ធសភា*

ក្រៀល បានរាយការណ៍យ៉ាងលម្អិតអំពីទិដ្ឋភាពជារួម ការអនុវត្តតួនាទី ភារកិច្ច ដោយមានការយកចិត្តទុកដាក់ប្រុងប្រយ័ត្នខ្ពស់ ព្រមទាំងបញ្ជាក់ច្បាស់អំពីលទ្ធផលសម្រេចបាន តាមការណែនាំរបស់ថ្នាក់ដឹកនាំ នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍។ ជាមួយគ្នានោះ លោកវរសេនីយ៍ឯកក៏បានបញ្ជាក់ផងដែរអំពីការខ្វះខាតខ្លះៗពាក់ព័ន្ធនឹងការលួចឆ្លងដែនខុសច្បាប់របស់ឈ្មួញទុច្ចរិតគ្រឿងញៀនដោយមូលហេតុទីតាំងមានព្រៃច្រើន។

ក្រោយពីបានស្ដាប់របាយការណ៍ដ៏ក្បោះក្បាយ លោកជំទាវកិត្តិនីតិកោសលបណ្ឌិត **ឌី ម៉ូរ៉ាស៊ី** បានអរគុណយ៉ាងជ្រាលជ្រៅ និងជូនពរដល់អាជ្ញាធរ និងកងកម្លាំងនគរបាលឈរជើងនៅច្រកទ្វារព្រំដែនអន្តរជាតិត្រពាំងក្រៀលទាំងអស់ សូមមានសុខភាពល្អ សុភមង្គល និងទទួលជោគជ័យថែមទៀតក្នុងការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន។ លោកជំទាវកិត្តិនីតិកោសលបណ្ឌិត ក៏បានស្នើសុំការអនុញ្ញាតឱ្យគណៈប្រតិភូព្រឹទ្ធសភាចុះទៅមើលសកម្មភាពអនុវត្តការងារជាក់ស្ដែងនៅច្រកទ្វារព្រំដែនដោយផ្ទាល់ផងដែរ៕

(អត្ថបទ និងរូបភាព៖ នុត សច្ចៈ)



*លោកជំទាវកិត្តិនីតិកោសលបណ្ឌិត ឌី ម៉ូរ៉ាស៊ី ប្រគល់វត្ថុអនុស្សាវរីយ៍ និងក្រមាដល់អាជ្ញាធរច្រកទ្វារព្រំដែនអន្តរជាតិត្រពាំងក្រៀល*



*គណៈប្រតិភូគណៈកម្មការទី៥ព្រឹទ្ធសភា ថតរូបអនុស្សាវរីយ៍ជាមួយអាជ្ញាធរច្រកទ្វារព្រំដែនអន្តរជាតិត្រពាំងក្រៀល*

# គណៈកម្មការទី៧ព្រឹទ្ធសភា ចុះឈ្វេងយល់អំពីវិស័យពាក់ព័ន្ធ ជាសមត្ថកិច្ចរបស់ខ្លួន នៅខេត្តក្រចេះ និងខេត្តត្បូងឃ្មុំ




*គណៈប្រតិភូគណៈកម្មការទី៧ព្រឹទ្ធសភា ជួបពិភាក្សាការងារជាមួយមន្ទីរពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការទី៧ព្រឹទ្ធសភា*

កាលពីថ្ងៃទី១៣ ដល់ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៣ គណៈប្រតិភូគណៈកម្មការអប់រំ យុវជន កីឡា ធម្មការ សាសនា វប្បធម៌ វិចិត្រសិល្បៈ និងទេសចរណ៍ នៃព្រឹទ្ធសភា (គណៈកម្មការទី៧) ដឹកនាំដោយឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ម៉ុម ជឹមហ៊ុយ** ប្រធានគណៈកម្មការ បានអញ្ជើញចុះបំពេញបេសកកម្មឈ្វេងយល់ពីវឌ្ឍនភាពការងារ បញ្ហាប្រឈម វិស័យពាក់ព័ន្ធជាសមត្ថកិច្ចរបស់គណៈកម្មការ និងទិសដៅការងារបន្តរបស់ខេត្តក្រចេះ និងខេត្តត្បូងឃ្មុំ។

ក្នុងឱកាស នៃការចុះបំពេញបេសកកម្មនោះ នារសៀលថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២៣ គណៈប្រតិភូគណៈកម្មការទី៧ព្រឹទ្ធសភា បានអញ្ជើញជួបពិភាក្សាការងារជាមួយនឹងមន្ទីរអប់រំ យុវជន និងកីឡា មន្ទីរធម្មការ និងសាសនា មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ មន្ទីរទេសចរណ៍ និងមន្ត្រីពាក់ព័ន្ធជុំវិញមន្ទីរទាំង៤ ដើម្បីឈ្វេងយល់ពីវឌ្ឍនភាពការងារ បញ្ហាប្រឈម ទិសដៅការងារបន្តរបស់មន្ទីរដែលវិស័យពាក់ព័ន្ធជាសមត្ថកិច្ចរបស់គណៈកម្មការ នៅសាលប្រជុំមន្ទីរអប់រំ យុវជន និងកីឡា ខេត្តក្រចេះ។

បន្ទាប់មកនាព្រឹកថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២៣ គណៈប្រតិភូគណៈកម្មការទី៧ព្រឹទ្ធសភា ដឹកនាំដោយឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ម៉ុម ជឹមហ៊ុយ** ប្រធានគណៈកម្មការ បានអញ្ជើញជួបពិភាក្សាការងារជាមួយនឹងអាជ្ញាធរខេត្តក្រចេះ ដឹកនាំដោយឯកឧត្តម **វ៉ា ថន** អភិបាល នៃគណៈអភិបាលខេត្ត និងមន្ទីរជំនាញពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ នៅសាលាខេត្តក្រចេះ។

ក្នុងឱកាសនោះ ឯកឧត្តម **វ៉ា ថន** អភិបាល នៃគណៈអភិបាលខេត្តក្រចេះ បានមានមតិស្វាគមន៍ និងជម្រាបជូនដោយសង្ខេបអំពីស្ថានភាពភូមិសាស្ត្រ ប្រជាសាស្ត្រ និងអំពីការងារពាក់ព័ន្ធនឹងជំនាញគណៈកម្មការទី៧ព្រឹទ្ធសភា រួមមានដូចខាងក្រោម៖

**១**-អំពីលក្ខណៈភូមិសាស្ត្រ និងប្រជាសាស្ត្រ

**២**-អំពីវិស័យអប់រំ យុវជន និងកីឡា




*គណៈប្រតិភូគណៈកម្មការទី៧ព្រឹទ្ធសភា ជួបពិភាក្សាការងារជាមួយអាជ្ញាធរខេត្តក្រចេះ*

៣-អំពីវិស័យធម្មការ និងសាសនា

៤-អំពីវិស័យវប្បធម៌ និងវិចិត្រសិល្បៈ

៥-អំពីវិស័យទេសចរណ៍។

ក្រោយពីស្ដាប់សេចក្ដីរាយការណ៍របស់ឯកឧត្តមអភិបាលខេត្តរួចមក ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ម៉ុម ជឹមហ៊ុយ** បានមានប្រសាសន៍ពាំនាំនូវការផ្ដាំផ្ញើសួរសុខទុក្ខពីសំណាក់ថ្នាក់ដឹកនាំព្រឹទ្ធសភា ជូនចំពោះថ្នាក់ដឹកនាំខេត្ត មន្ត្រីរាជការ និងប្រជាពលរដ្ឋទូទាំងខេត្តក្រចេះ។ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត បានកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះរបាយការណ៍ប្រកបដោយក្ដីសង្ឃឹមរបស់គណៈកម្មការក្នុងការចូលរួមអភិវឌ្ឍប្រទេសជាតិ។ ទន្ទឹមនេះ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត បានបញ្ជាក់ថា សភាពការណ៍សកលលោកប្រកបដោយភាពស្មុគស្មាញ ភាពមិនប្រាកដប្រជា នៃសង្គ្រាម ការប្រកួតប្រជែងភូមិសាស្ត្រនយោបាយ បញ្ហាសុខភាពសាធារណៈ និងការប្រែប្រួលអាកាសធាតុ និងបានផ្ដល់នូវអនុសាសន៍គន្លឹះមួយចំនួនពាក់ព័ន្ធនឹងវិស័យ សម្រាប់ជាត្រីវិស័យយកទៅអនុវត្តការងារបន្តឱ្យសម្រេចបានតាមផែនការយុទ្ធសាស្ត្ររបស់ខ្លួន។

ក្នុងឱកាសបំពេញបេសកកម្មនៅខេត្តក្រចេះ នារសៀលថ្ងៃដដែល គណៈប្រតិភូគណៈកម្មការទី៧ព្រឹទ្ធសភា ដឹកនាំដោយឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ម៉ុម ជឹមហ៊ុយ** ប្រធានគណៈកម្មការ អមដំណើរដោយឯកឧត្តមអភិបាលរងខេត្ត និងមន្ទីរជំនាញពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ បានអញ្ជើញទស្សនាវត្តសសរ១០០ និងតំបន់រមណីយដ្ឋានទេសចរណ៍អន្លង់ផ្សោត ស្ថិតនៅក្នុងស្រុកសំបូរ ខេត្តក្រចេះ។

បន្ទាប់មកនៅព្រឹកថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៣ គណៈប្រតិភូគណៈកម្មការទី៧ព្រឹទ្ធសភា ដឹកនាំដោយឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការ តំណាងឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ម៉ុម ជឹមហ៊ុយ** ប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា បានអញ្ជើញជួបពិភាក្សាការងារជាមួយនឹងអាជ្ញាធរខេត្តត្បូងឃ្មុំ ដឹកនាំដោយឯកឧត្តម **ពាង ណារិទ្ធ** អភិបាលស្ដីទី នៃគណៈអភិបាលខេត្ត និងមន្ទីរជំនាញពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ នៅសាលាខេត្តត្បូងឃ្មុំ។

ក្នុងឱកាសនោះ ឯកឧត្តម **ពាង ណារិទ្ធ** អភិបាលស្ដីទីនៃគណៈអភិបាលខេត្តត្បូងឃ្មុំ និងមន្ទីរជំនាញពាក់ព័ន្ធ បានធ្វើសេចក្ដីរាយការណ៍អំពីស្ថានភាពភូមិសាស្ត្រ និងប្រជាសាស្ត្រ ការងារអប់រំ ការងារធម្មការ និងសាសនា ការងារវប្បធម៌ និងវិចិត្រសិល្បៈ ការងារទេសចរណ៍ និងទិសដៅការងារបន្ត ព្រមទាំងបញ្ហាប្រឈម និងសំណូមពរនានា ដែលពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ បានជួបប្រទះក្នុងការអនុវត្តការងារនាពេលកន្លងមក។ ឯឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា បានថ្លែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះការខិតខំបំពេញការងារពាក់ព័ន្ធវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការបានយ៉ាងល្អប្រសើរ មានការរីកចម្រើន និងអភិវឌ្ឍន៍។

ដោយឡែក បញ្ហាប្រឈម និងសំណូមពរនានា យើងត្រូវខិតខំដោះស្រាយរួមគ្នា ចំពោះបញ្ហាដែលនៅសេសសល់ គណៈកម្មការទី៧ព្រឹទ្ធសភានឹងធ្វើរបាយការណ៍សរុបរាយការណ៍ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ក្រសួង និងស្ថាប័នពាក់ព័ន្ធ ដើម្បីឱ្យខិតខំដោះស្រាយឱ្យគ្រប់វិស័យទាំងអស់មានការអភិវឌ្ឍ។៚

(អត្ថបទ និងរូបភាព៖ វង់ សុជាតិ)





*គណៈប្រតិភូគណៈកម្មការទី៧ព្រឹទ្ធសភា ជួបជាមួយអាជ្ញាធរខេត្តត្បូងឃ្មុំ*

# ក្រុមសមាជិកាព្រឹទ្ធសភា អញ្ជើញជួបសំណេះសំណាល សួរសុខទុក្ខយុទ្ធជនពិការ និងអតីតយុទ្ធជន ខេត្តកំពង់ឆ្នាំង



*លោកជំទាវ មាន សំអាន សំណេះសំណាលជាមួយយុទ្ធជនពិការ និងអតីតយុទ្ធជន*

ដើម្បីរំឭកដល់គុណូបការៈភាពដ៏មោះមុត និងគុណបំណាច់ដ៏ធំធេងរបស់វីរយុទ្ធជន យុទ្ធនារី នៃកងកម្លាំងប្រដាប់អាវុធ និងប្រជាពលរដ្ឋគ្រប់ស្រទាប់ដែលបានពលិកម្មយ៉ាងអង់អាចក្លាហាន បូជាសាច់ស្រស់ ឈាមស្រស់ ដើម្បីបុព្វហេតុជាតិមាតុភូមិ ក្រុមសមាជិកាព្រឹទ្ធសភា ដឹកនាំដោយលោកជំទាវ **មាន សំអាន** ប្រធានក្រុមសមាជិកាព្រឹទ្ធសភា និងជាប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាល សួរសុខទុក្ខបងប្អូនយុទ្ធជនពិការ និងអតីតយុទ្ធជនក្រីក្រចំនួន១០០គ្រួសារ នាព្រឹកថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២៣ នៅសមាគមអតីតយុទ្ធជនកម្ពុជា ដែលស្ថិតក្នុងភូមិអូរកាខុប ឃុំក្រាំងល្វា ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ដោយមានការអញ្ជើញចូលរួមពីសមាជិកាព្រឹទ្ធសភា រដ្ឋសភា ឯកឧត្តមអភិបាលរង នៃគណៈអភិបាលខេត្ត អនុប្រធានកិត្តិយសសាខាសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ មេបញ្ជាការតំបន់ប្រតិបត្តិការសឹករង និងជាប្រធានសមាគមអតីតយុទ្ធជនកម្ពុជា បងប្អូនយុទ្ធជនពិការ និងអតីតយុទ្ធជន ព្រមទាំងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ផងដែរ។

ក្នុងឱកាសនោះដែរ លោកជំទាវ **មាន សំអាន** ប្រធានក្រុមសមាជិកាព្រឹទ្ធសភា និងជាប្រធានគណៈកម្មការទី៨ព្រឹទ្ធសភាបានមានប្រសាសន៍ពាំនាំនូវការសាកសួរសុខទុក្ខពីសំណាក់ថ្នាក់ដឹកនាំព្រឹទ្ធសភា ផ្ញើសួរសុខទុក្ខប្រកបដោយមនោសញ្ចេតនាជូនដល់បងប្អូនយុទ្ធជនពិការ និងអតីតយុទ្ធជន។

លោកជំទាវបានរំលឹកប្រវត្តិនៃការប្រារព្ធខួបទិវាអតីតយុទ្ធជនកម្ពុជា គឺដើម្បីរំលឹកដល់គុណូបការៈភាពដ៏មោះមុត ពលិកម្មប្រកបដោយស្មារតីស្នេហាជាតិរបស់អតីតវីរយុទ្ធជន យុទ្ធនារី និងប្រជាពលរដ្ឋ នៅគ្រប់ដំណាក់កាលនៃប្រវត្តិសាស្ត្រ គឺបានរួមចំណែកយ៉ាងសំខាន់ក្នុងកិច្ចការពារបូរណភាពទឹកដី ការកសាងសុខសន្តិភាព និងស្ថិរភាពសង្គម សម្រាប់ព្រះរាជាណាចក្រកម្ពុជា សំដៅធានាឱ្យមានការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ដើម្បីជាឧត្តមប្រយោជន៍សម្រាប់ជាតិមាតុភូមិ និងប្រជាជនកម្ពុជា។





*ទិដ្ឋភាពក្នុងពិធីសំណេះសំណាល*



*លោកជំទាវ មាន សំអាន អញ្ជើញចែកអំណោយជូនយុទ្ធជនពិការ និងអតីតយុទ្ធជន*

លោកជំទាវបានបញ្ជាក់ថា បច្ចុប្បន្ននេះ អតីតយុទ្ធជនចំនួន១០៦.៩០៥នាក់ ព្រមទាំងអ្នកនៅក្នុងបន្ទុកចំនួន ១៥៣.៦១០នាក់ កំពុងទទួលប្រាក់របបសន្តិសុខសង្គមប្រចាំខែពីរដ្ឋ។ គិតចាប់ពីខែមករា ឆ្នាំ២០២៣តទៅ រាជរដ្ឋាភិបាលបានដំឡើងប្រាក់របបសន្តិសុខសង្គមប្រចាំខែជូននិវត្តជន ជនបាត់បង់សមត្ថភាពការងារ និងជនពិការដែលទាបជាង ឬស្មើនឹង៦៩ម៉ឺនរៀល ត្រូវបន្ថែមឱ្យដល់ត្រឹម ៧៧ម៉ឺនរៀលក្នុងមួយខែ ក្នុងនោះប្រាក់វិភាជន៍គ្រួសារ ប្រាក់បំណាច់គ្រួសារ និងកូនប្រចាំខែរបស់អតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជន និងប្រាក់ឧបត្ថម្ភផ្សេងៗ ត្រូវបានកំពុងអនុវត្តដូចប្រាក់វិភាជន៍គ្រួសារប្រចាំខែរបស់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធផងដែរ។

លោកជំទាវ **មាន សំអាន** បានមានប្រសាសន៍ផ្តាំផ្ញើបងប្អូនអតីតយុទ្ធជនកម្ពុជា សូមបន្តរក្សាស្មារតីវីរភាពដ៏ឧត្តុង្គឧត្តម និងសេចក្តីថ្លៃថ្នូរ ជាពលរដ្ឋឆ្នើមរបស់ជាតិមាតុភូមិ ដើម្បីបន្តធ្វើជាគំរូល្អក្នុងសង្គមជាតិ។ ប្រជាជនកម្ពុជាទូទាំងប្រទេស ពិតជាចងចាំជានិច្ចនូវការលះបង់ និងគុណបំណាច់ដ៏ធំធេងរបស់បងប្អូនអតីតយុទ្ធជនគ្រប់រូប ចំពោះជាតិមាតុភូមិ។

ក្នុងឱកាសដ៏ថ្លៃថ្លានោះដែរ ក្រុមសមាជិកាព្រឹទ្ធសភាក៏បាននាំយកអំណោយចែកជូនដល់បងប្អូនយុទ្ធជនពិការ និងអតីតយុទ្ធជនទាំង១០០គ្រួសារ ដោយក្នុងមួយគ្រួសារទទួលបាន៖ អង្ករ១បេ ត្រីខ១យួរ សៀងផ្អែម១គីឡូក្រាម ឆៃប៉ូវផ្អែម១គីឡូក្រាម ប៊ីចេង១កញ្ចប់ ប្រេងឆា១ដប ភួយ១ ក្រមា១ សារុង១ កាបូប និងថ្នាំពេទ្យចំនួន១កាបូប សាប៊ូដុសខ្លួន២ដុំ ម៉ាស់ក្មេង៥កញ្ចប់ ទឹកបរិសុទ្ធ នំប៉័ងទំពាំងបាយជូរ និងថវិកាចំនួន១០ម៉ឺនរៀល។ ដោយឡែកសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ស្រុកសាមគ្គីមានជ័យ ក្នុងម្នាក់ៗទទួលបាន៖ ត្រីខ១យួរ សៀងផ្អែម២គីឡូក្រាម ឆៃប៉ូវផ្អែម ១គីឡូក្រាម ប៊ីចេង១កញ្ចប់ ភួយ១ ក្រមា១ អាវយឺត១ ម៉ាស់ក្មេង៥កញ្ចប់ សៀវភៅ២ក្បាល ប៊ិក១ដើម រ៉ូលអន ១ទីប ក្រែមរ៉េវឡុន១ដើម ទឹកអប់១ដប ថ្នាំលាបសក់១ប្រអប់ សាប៊ូដុសខ្លួន២ដុំ កាបូប និងថ្នាំពេទ្យ១កាបូប ទឹកបរិសុទ្ធ និងនំប៉័ងទំពាំងបាយជូរ១ដុំ ព្រមទាំងថវិកា១០ម៉ឺនរៀលផងដែរ៕

(អត្ថបទ និងរូបភាព៖ អ៊ុក ប៉ូលីន)



*ក្រុមសមាជិកាព្រឹទ្ធសភា ថតរូបអនុស្សាវរីយ៍ជាមួយសមាជិការដ្ឋសភា និងអនុប្រធានកិត្តិយសសាខាសមាគមនារីកម្ពុជា*

# គណៈកម្មការទាំង១០ព្រឹទ្ធសភាចូលរួមកិច្ចប្រជុំនានា



❈នាព្រឹកថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៣ ឯកឧត្តម កិត្តិសេដ្ឋាបណ្ឌិត **ជា ចេដ្ឋ** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភាបានដឹកនាំកិច្ចប្រជុំគណៈកម្មការទី២ព្រឹទ្ធសភា ដើម្បីពិភាក្សាអំពីការងាររបស់គណៈកម្មការ និងការត្រៀមចុះបេសកកម្មទៅខេត្តព្រៃវែង នៅចន្លោះសម័យប្រជុំព្រឹទ្ធ-សភា នៅសាលប្រជុំគណៈកម្មការទី២ព្រឹទ្ធសភា។

❈ឯកឧត្តម **សុខ ឥសាន** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភាបានដឹកនាំកិច្ចប្រជុំដូចខាងក្រោម៖



-កិច្ចប្រជុំគណៈកម្មការទី៤ព្រឹទ្ធសភា នាព្រឹកថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៣ ដើម្បីពិនិត្យពិភាក្សាលើ៖

១-សេចក្ដីព្រាងច្បាប់ស្ដីពី ការបង្កើតក្រសួងអធិការកិច្ច

២-សេចក្ដីព្រាងច្បាប់ស្ដីពី ការបង្កើតរដ្ឋលេខាធិការ-ដ្ឋានកិច្ចការព្រំដែន។



-កិច្ចប្រជុំរវាងគណៈកម្មការទី៤ព្រឹទ្ធសភាជាមួយនឹងតំណាងរាជរដ្ឋាភិបាល ដឹកនាំដោយឯកឧត្តម **ហួត ហាក់** រដ្ឋមន្ត្រីក្រសួងអធិការកិច្ច និងសហការី ដើម្បីពិនិត្យសិក្សាលើសេចក្ដីព្រាងច្បាប់ស្ដីពី ការបង្កើតក្រសួងអធិការកិច្ច នាព្រឹកថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៣ នៅសាលប្រជុំពិសេសព្រឹទ្ធសភា។



-កិច្ចប្រជុំរវាងគណៈកម្មការទី៤ព្រឹទ្ធសភាជាមួយនឹងតំណាងរាជរដ្ឋាភិបាល ដឹកនាំដោយឯកឧត្តម **ឡាំ ជា** រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន និងសហការី ដើម្បីពិនិត្យសិក្សាលើសេចក្ដីព្រាងច្បាប់ ស្ដីពីការបង្កើតរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន នារសៀលថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៣ នៅសាលប្រជុំពិសេសព្រឹទ្ធសភា។



-កិច្ចប្រជុំក្រុមសមាជិកព្រឹទ្ធសភាក្រុមទី២ ដើម្បីពិនិត្យពិភាក្សាលើសេចក្ដីព្រាងច្បាប់ស្ដីពី ការបង្កើតក្រសួងអធិ-ការកិច្ច និងសេចក្ដីព្រាងច្បាប់ស្ដីពីការបង្កើតរដ្ឋលេខាធិ-ការដ្ឋានកិច្ចការព្រំដែននារសៀលថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ នៅសាលប្រជុំគណៈកម្មការទី៤ព្រឹទ្ធសភា។

❈នាថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៣ ឯកឧត្តម **អ៊ុក ច៊ុនឈឿន** ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភាបានដឹកនាំកិច្ចប្រជុំសមាជិកព្រឹទ្ធសភាក្រុមទី៣ នៅសាលប្រជុំគណៈ-កម្មការទី៦ព្រឹទ្ធសភា ដើម្បីពិនិត្យត្រៀមផ្ដល់យោបល់ក្នុង



អង្គប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៤ លើះ

១-សេចក្ដីព្រាងច្បាប់ស្ដីពី ការបង្កើតក្រសួងអធិការកិច្ច

២-សេចក្ដីព្រាងច្បាប់ស្ដីពី ការបង្កើតរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន។



❈នាថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២៣ ឯកឧត្ដមកិត្តិនីតិកោសលបណ្ឌិត **ម៉ុម ឌឹមហ៊ុយ** ប្រធានគណៈកម្មការទី៧ព្រឹទ្ធសភាបានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៧ព្រឹទ្ធសភា ដើម្បីពិនិត្យ ពិភាក្សា និងកែសម្រួលខ្លឹមសាររបាយការណ៍ស្ដីពី ដំណើរចុះបំពេញបេសកកម្ម ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងារ បញ្ហាប្រឈម និងចក្ខុវិស័យទៅមុខរបស់អាជ្ញាធរខេត្ត និងមន្ទីរពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ នៅខេត្តក្រចេះ និងខេត្តត្បូងឃ្មុំ នៅសាលប្រជុំគណៈកម្មការទី៧ព្រឹទ្ធសភា។



❈នាព្រឹកថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៣ លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភាបានដឹកនាំកិច្ចប្រជុំគណៈកម្មការទី៨ព្រឹទ្ធសភា ដើម្បីពិនិត្យពិភាក្សាលើះ

១-របាយការណ៍ទូទាត់ចំណូល ចំណាយរបស់គណៈកម្មការប្រចាំត្រីមាសទី៣ ឆ្នាំ២០២៣

២-របាយការណ៍សកម្មភាពការងាររបស់គណៈកម្មការចន្លោះសម័យប្រជុំលើកទី១០ និងលើកទី១១ ព្រឹទ្ធសភានីតិកាលទី៤

៣-អំពីសមិទ្ធផលរបស់គណៈកម្មការទី៨ព្រឹទ្ធសភានីតិកាលទី៤

៤-ខ្លឹមសារវីដេអូស្ដីពី សមិទ្ធផលសំខាន់ៗរបស់គណៈកម្មការទី៨ព្រឹទ្ធសភា នីតិកាលទី៤

៥-បញ្ហាផ្សេងៗ។

❈ឯកឧត្ដម **គង់ សារាជ** ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភាបានដឹកនាំកិច្ចប្រជុំដូចខាងក្រោមះ



-កិច្ចប្រជុំគណៈកម្មការទី៩ព្រឹទ្ធសភា ដើម្បីពិភាក្សាការត្រៀមចុះបេសកកម្មសិក្សាឈ្វេងយល់ការងារពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ ទៅខេត្តសៀមរាប នារសៀលថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២៣ នៅសាលប្រជុំគណៈកម្មការទី៩ព្រឹទ្ធសភា។



-កិច្ចប្រជុំក្រុមសមាជិកព្រឹទ្ធសភាក្រុមទី៥ នារសៀលថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ នៅសាលប្រជុំគណៈកម្មការទី១០ព្រឹទ្ធសភា ដើម្បីពិនិត្យពិភាក្សាលើះ

១-ត្រៀមឱ្យយោបល់លើសេចក្ដីព្រាងច្បាប់ស្ដីពី ការបង្កើតក្រសួងអធិការកិច្ច

២-ត្រៀមឱ្យយោបល់លើសេចក្ដីព្រាងច្បាប់ស្ដីពី ការបង្កើតរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន និង

៣-បញ្ហាផ្សេងៗ

❈នារសៀលថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភាបានដឹកនាំកិច្ចប្រជុំគណៈកម្មការទី១០ព្រឹទ្ធសភា ដើម្បីពិនិត្យសម្រេចរបាយការណ៍ថវិកា និងរបាយការណ៍ស្តីពី សកម្មភាពលទ្ធផលការងារប្រចាំខែកញ្ញា និងលើកទិសដៅការងារបន្ត នៅសាលប្រជុំគណៈកម្មការទី១០ព្រឹទ្ធសភា។



❈នាព្រឹកថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២៣ ឯកឧត្តម **ខៀវ មុត** អនុប្រធានគណៈកម្មការទី១ព្រឹទ្ធសភាបានដឹកនាំកិច្ចប្រជុំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ ដើម្បីពិនិត្យអនុម័តលើរបាយការណ៍ស្តីពី លទ្ធផលការងារប្រចាំនីតិកាលទី៤ព្រឹទ្ធសភា (២០១៨-២០២៤) របស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ និងបញ្ហាផ្សេងៗ នៅសាលប្រជុំគណៈកម្មការទី១ព្រឹទ្ធសភា។

❈ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភាបានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៧ព្រឹទ្ធសភា ដើម្បីៈ



-ពិភាក្សា និងកែសម្រួលខ្លឹមសារឯកសារ សម្រាប់ត្រៀមចុះបំពេញបេសកកម្មទៅខេត្តក្រចេះ និងខេត្តត្បូងឃ្មុំ នាថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០២៣ នៅសាលប្រជុំគណៈកម្មការទី៧ព្រឹទ្ធសភា។



-ពិនិត្យ និងកែសម្រួលខ្លឹមសាររបាយការណ៍ស្តីពី វឌ្ឍនភាពការងារ បញ្ហាប្រឈម និងចក្ខុវិស័យទៅមុខរបស់អាជ្ញាធរខេត្ត និងមន្ទីរពាក់ព័ន្ធវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ នៅខេត្តក្រចេះ និងខេត្តត្បូងឃ្មុំ ក្រោយដំណើរចុះបំពេញបេសកកម្ម នាថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២៣ នៅសាលប្រជុំគណៈកម្មការទី៧ព្រឹទ្ធសភា។



❈នាថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២៣ ឯកឧត្តម **ឆាយ ថណ្ណា** លេខាធិការគណៈកម្មការទី៥ព្រឹទ្ធសភាបានអនុញ្ញាតឱ្យឯកឧត្តម **ផាវ៉ា មង្គល** រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងប្រតិភូចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ នៅសាលប្រជុំគណៈកម្មការទី៥ព្រឹទ្ធសភា៕

## ការទទួលពាក្យបណ្តឹង

❈ក្នុងខែកញ្ញា ឆ្នាំ២០២៣ គណៈកម្មការទី១ព្រឹទ្ធសភាបានធ្វើកំណត់បង្ហាញពាក្យបណ្តឹងចំនួន២ករណី (សល់ពីខែសីហា) បញ្ជូនពាក្យបណ្តឹងចេញទៅក្រសួង ខេត្ត និងស្ថាប័នពាក់ព័ន្ធចំនួន២ករណី កំពុងពិនិត្យសិក្សាចំនួន២ករណី ឆ្លើយតបទៅម្ចាស់បណ្តឹង(ផ្តល់ព័ត៌មានទៅម្ចាស់បណ្តឹង)ចំនួន២ករណី ទទួលលិខិតឆ្លើយតបពីការដោះស្រាយពីស្ថាប័នពាក់ព័ន្ធចំនួន២ករណី ព្រមទាំងបានទទួលឯកសារជូនជ្រាបពីក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការចំនួន៤ករណី៕

# សមាជិក សមាជិកាព្រឹទ្ធសភាបំពេញការងារនៅតាមបណ្តាភូមិភាគទាំង៨

❈ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ជា ខេង** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញ៖



-ចុះបេសកកម្មសិក្សាឈ្វេងយល់ស្តីពី “ការអភិវឌ្ឍមូលដ្ឋាន និងបម្រើសេវាជូនប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាពធានាបានសុខសន្តិភាព” នៅខេត្តព្រៃវែង ពីថ្ងៃទី១៣ ដល់ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៣។



-ជាអធិបតីភាពក្នុងកិច្ចប្រជុំបូកសរុបការងារបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ កន្លងទៅ និងពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះអ្នកបោះឆ្នោតឆ្នាំ២០២៣ ជាមួយនឹងប្រធានក្រុមអ្នកច្បាប់ខណ្ឌទាំង១៤ នៅរាជធានីភ្នំពេញ នាព្រឹកថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២៣។

❈ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងដឹកនាំក្រុមការងារបច្ចេកទេសចុះពិនិត្យដំណាំកសិកម្ម កសិ-ឧស្សាហកម្ម និងហេដ្ឋារចនាសម្ព័ន្ធផ្លូវ លូ ស្ពាន និងទំនប់ទឹក នៅឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ និងចុះពិនិត្យរថយន្តតបណ្តាញអគ្គិសនីសម្រាប់ផ្គត់ផ្គង់ជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃ ព្រមទាំងដឹកនាំកម្មករ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងប្រជាពលរដ្ឋ ចូលរួមដាំដើមឈើចម្រុះនៅតំបន់អភិវឌ្ឍន៍កសិ-ទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ និងប្រគេនកូនដើមឈើចម្រុះដល់ព្រះសង្ឃ **គូ សុភាព** គង់នៅវត្តគល់ទទឹងផងដែរ នៅឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋអញ្ជើញមកសម្រាកកម្សាន្ត និងទស្សនាសួនសត្វ ព្រះវិហារ និងសហចេតិយ នៅឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នារសៀលថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងដឹកនាំក្រុមការងារបច្ចេកទេសសំណង់សាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវ ទឹក ភ្លើង នៅលើផ្ទៃដី១៧២ហិកតា ដើម្បីត្រៀមបម្រើសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ នៅឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២៣។

-ចូលរួមពិធីសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋ និងអ្នកជំងឺសរុបចំនួន១០០នាក់ នៅក្នុងមន្ទីរពេទ្យ BIOMEDIC នៅភ្នំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋ ព្រមទាំងនាំយកអំណោយ និងឧបត្ថម្ភថវិកាមួយចំនួន នៅវត្តព្រៃរុន ឃុំស្រង៉ែ ស្រុកទ្រាំង ខេត្តតាកែវ នារសៀលថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងចុះពិនិត្យមើលក្រុមការងាររោងចក្រផលិតចំណីសត្វ ចម្ការដូងក្រអូប និងចុះពិនិត្យស្ពានទំនប់ទឹកសម្រាប់បំពេញសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋរស់នៅក្នុងតំបន់ និងចូលរួមពិធីពិសាអាហារសាមគ្គីជាមួយប្រជាពលរដ្ឋផងដែរ នៅឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ នាថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋបើកបររថយន្តដឹកពោត និងដំឡូងមី យកមកផ្គត់ផ្គង់ឱ្យរោងចក្រផលិតចំណីសត្វ ព្រមទាំងបានឧបត្ថម្ភថវិកាមួយចំនួននៅឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ នា

ថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងចុះពិនិត្យមើលទំនប់ទឹក និងហេដ្ឋារចនាសម្ព័ន្ធនានា នៅឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋ ព្រមទាំងចុះណែនាំពួកគាត់អំពីការថែទាំដី ដើម្បីដាំដំណាំស្រូវទទួលបានផលល្អ នៅឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋមកសម្រាកកម្សាន្ត និងទស្សនាសួនសត្វ ព្រះវិហារ និងសហាចេតិយ ព្រមទាំងណែនាំពួកគាត់អំពីការបណ្ដុះ និងថែទាំកូនដើមឈើ នៅឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងចុះពិនិត្យមើលទំនប់ទឹកតាកឹងដែលអាចស្តុកទឹកបានចំនួន ៣០០.០០០ម៉ែត្រគូប ដើម្បីស្ដុបទឹកសម្រាប់បម្រើសេចក្ដីត្រូវការប្រជាពលរដ្ឋ និងពិនិត្យស្ថានភាពប្រព័ន្ធបង្ហូរទឹកលូ ទំនប់ទឹក និងចម្ការដូងក្រអូប នៅភូមិមនោរម្យ ឃុំតានៃ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ នាព្រឹកថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៣។

-ទទួលជួបក្រុមវិនិយោគជនជាតិចិន ដែលមានបំណងចង់វិនិយោគលើវិស័យឧស្សាហកម្មកែច្នៃ នៅព្រះរាជាណាចក្រកម្ពុជា នៅឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ នាថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសុខទុក្ខប្រជាពលរដ្ឋកំពុងប្រមូលផលស្រូវ នៅជើងភ្នំសំពៅ នៅស្រុកបាណន់ ខេត្តបាត់ដំបង នាព្រឹកថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខអាជីវករលក់ដូរក្នុងផ្សារចាស់ ក្រុងបាត់ដំបង ខេត្តបាត់ដំបង នារសៀលថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងដឹកនាំក្រុមអ្នកជំនាញកសិកម្ម ចូលរួមដាំកូនដើមឈើះ អូញម៉ូញ ត្របែកព្រៃ និងសាគូរ៉ា ដើម្បីចូលរួមថែរក្សាការពារព្រៃឈើ និងបរិស្ថានជាមួយរាជរដ្ឋាភិបាល នៅឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២៣។

-ទទួលជួបក្រុមអ្នកវិនិយោគជប៉ុនដែលមានបំណងបណ្ដាក់ទុនវិនិយោគ សិក្សាឈ្វេងយល់លើវិស័យកសិកម្ម និងកសិ-ឧស្សាហកម្មនៅព្រះរាជាណាចក្រកម្ពុជា នៅហាងកាហ្វេដូងប្រេង ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ នាព្រឹកថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងចុះពិនិត្យមើលមន្ទីរពេទ្យ ម៉ុង ឫទ្ធី សែនជ័យ និងហេដ្ឋារចនាសម្ព័ន្ធនានា នៅតំបន់អភិវឌ្ឍន៍កសិ-ទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ នៅឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២៣។

ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងដឹកនាំក្រុមការងារបច្ចេកទេសសំណង់ និងកសិកម្ម ព្រមទាំងចុះពិនិត្យសិក្សាឈ្វេងយល់សមិទ្ធផលបន្ថែមទៀត នៅឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៣។

❋នាថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០២៣ ឯកឧត្តម **សុខ ឥសាន** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ សង្កាត់ នៃស្រុកពាមរក៍ នៅសាលាខេត្តព្រៃវែង។

❋នាថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២៣ ឯកឧត្តម **អ៊ុក ប៊ុនឈឿន** ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាលប្រជាពលរដ្ឋ នៅឃុំដា ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។



❋នាថ្ងៃទី២៩ ខែសីហា និងថ្ងៃទី៥ ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២៣ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ម៉ុម ជឹមហ៊ុយ** ប្រធានគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាល និងពិភាក្សាការងារជាមួយនឹងក្រុមប្រឹក្សាសង្កាត់កំបូល សង្កាត់កន្ទោក និងសង្កាត់ប្រទះឡាង ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួន នៅខណ្ឌកំបូល រាជធានីភ្នំពេញ។

❋នាថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២៣ លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា និងលោកជំទាវ **មុំ សណ្ដាប់** លេខាធិការគណៈកម្មការទី៨



ព្រឹទ្ធសភា បានអញ្ជើញជាអធិបតីភាពក្នុងពិធីក្រុងពាលី បញ្ចុះបឋមសិលាកសាងកុដិ និងបុណ្យផ្កាប្រាក់សាមគ្គី វេរប្រគេនដើម្បីប្រមូលបច្ច័យកសាងសមិទ្ធផលនានា នៅក្នុងវត្តវារីផាសុខារាម (ហៅវត្តទឹកជុំ) នៅភូមិទឹកជុំ ឃុំអភិវឌ្ឍន៍ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង។

❈នាថ្ងៃទី២៦ និងថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២៣ លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាល និងសួរ-សុខទុក្ខប្រជាពលរដ្ឋតាមខ្នងផ្ទះ នៅភូមិស្វាយទាប និងភូមិអំពិលក្រៅ ឃុំអំពិលក្រៅ ស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង។

❈ឯកឧត្តម **ឈួន ឡេង** អនុប្រធានគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមប្រជុំបូកសរុបលទ្ធផលការងារបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ក្រោមអធិបតីភាពឯកឧត្តម **ពេជ ជីវ័ន្ត** ប្រធានក្រុមការងារស្រុកពាមជរ ខេត្តព្រៃវែង នាថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២៣។

-ជាអធិបតីភាពក្នុងកិច្ចប្រជុំការងារមូលដ្ឋានឃុំឫស្សី-ស្រុក ស្រុកពាមជរ ដើម្បីប្រជុំបូកសរុបលទ្ធផលការងារបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ នៅសាលាស្រុកពាមជរ ខេត្តព្រៃវែង នាថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០២៣។

❈នាថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២៣ ឯកឧត្តម **ប៉ុល លឹម** អនុប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងស្រុកកំរៀង ខេត្តបាត់ដំបង។

❈ឯកឧត្តម **អោយ ខន** អនុប្រធានគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញ៖

-ជាគណៈអធិបតីភាពប្រជុំបូកសរុបដកពិសោធន៍សកម្មភាព និងលទ្ធផលការងារយុទ្ធនាការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ នៅក្រុងខេមរៈភូមិន្ទ ខេត្តកោះកុង នាថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីផ្សព្វផ្សាយអំពីលទ្ធផល នៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ ឆ្នាំ២០២៣ នៅស្រុកថ្មបាំង ស្រុកបូទុមសាគរ ស្រុកស្រែអំបិល និងស្រុកកោះកុង ខេត្តកោះកុង នាថ្ងៃទី៨ ដល់ថ្ងៃទី១០ និងថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២៣។



❈នារសៀលថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៣ ឯកឧត្តម **ប្រាក់ ចំរើន** អនុប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញនាំយកអំណោយអង្ករចំនួន១០០បាវ ស្មើនឹង ២.០០០គីឡូក្រាម ទុកសម្រាប់ចែកជូនដល់ជនចាស់ជរា និងអ្នកមានជំងឺ ចំនួន៩០គ្រួសារ ក្នុងឱកាសបើកការដ្ឋានសាងសង់ផ្លូវ និងដាក់ប្រព័ន្ធលូ ចំនួន៤ខ្សែ នៅសង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ។



❈ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា និងលោកជំទាវ **មុំ សណ្ដាប់** លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធសពឯកឧត្តម **ផន ដាវី** សមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ បានទទួលមរណភាពក្នុងជន្មាយុ៦៤ឆ្នាំ ដោយរោគាពាធ នៅសង្កាត់ស្ទឹងមានជ័យទី១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ នាព្រឹកថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២៣។

❈ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញ៖



-ចូលរួមគោរពវិញ្ញាណក្ខន្ធសពលោកជំទាវ **ហ៊ុល សុធី** ភរិយា ឯកឧត្តម **រ័ត្ន សារិន** ទីប្រឹក្សារាជរដ្ឋាភិបាល បានទទួលមរណភាពក្នុងជន្មាយុ៧៤ឆ្នាំ ដោយរោគាពាធ នៅភូមិ៨ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ នាថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៣។



-ចុះសួរសុខទុក្ខលោកយាយចាស់ជរា និងពិការភ្នែក ព្រមទាំងឧបត្ថម្ភអង្ករ កន្សែងពោះគោ និងថវិកាមួយចំនួន នៅគេហដ្ឋានក្នុងសង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញញ នាថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៣។

❈ឯកឧត្តម **ម៉ែន-ស៊ីផាន់** អនុប្រធានគណៈកម្មការទី៩ព្រឹទ្ធសភាបានអញ្ជើញ៖

-នាំយកទេយ្យទាន និងបច្ច័យប្រគេនដល់ព្រះសង្ឃដែលគង់ចាំព្រះវស្សានៅវត្តព្រះពន្លា ឃុំព្រះពន្លា ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង នាថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២៣។

-ចូលរួមក្នុងពិធីពិសាអាហារសាមគ្គី អបអរសាទរពិធីប្រកាសចូលកាន់មុខតំណែង អភិបាលខេត្តស្វាយរៀង នៅសាលប្រជុំធំ ខេត្តស្វាយរៀង នាថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលនិស្សិតមហាវិទ្យាល័យកសិកម្ម នៃសាកលវិទ្យាល័យស្វាយរៀង នៅខេត្តស្វាយរៀង នាថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋក្នុងឃុំព្រះពន្លា ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង នាថ្ងៃទី២ និងថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២៣។

❈ឯកឧត្តម **ហែម ខន** អនុប្រធានគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបពិភាក្សាការងារជាមួយនឹងប្រធានមន្ទីរសុខាភិបាល និងប្រធានមន្ទីរផែនការ ដើម្បីត្រៀមរៀបចំកម្មវិធីសំណេះ-សំណាល និងសួរសុខទុក្ខមន្ត្រីរាជការចូលនិវត្តន៍មកពីមន្ទីរសុខាភិបាល និងមន្ទីរផែនការ ចំនួន២១០នាក់ នៅមន្ទីរសុខាភិបាលខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២៣។

-នាំយកចង្ហាន់ ទេយ្យវត្ថុ ទឹកបរិសុទ្ធ ទឹកក្រូច មី អង្ករ និងបច្ច័យមួយចំនួនប្រគេនដល់ព្រះសង្ឃក្នុងពិធីសូត្រមន្តសង្ឃទានជូនដល់លោក **ម៉ែន ខុន** អតីតប្រធានក្រុម-ប្រឹក្សាឃុំ ដែលកំពុងសម្រាកព្យាបាលជំងឺនៅគេហដ្ឋាន នៅសង្កាត់រកាធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ២០២៣។

❈នាថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២៣ ឯកឧត្តម **គិន ណែត** លេខាធិការគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញ នាំយកទៀនវស្សា និងទេយ្យវត្ថុប្រគេនព្រះសង្ឃដែលគង់ចាំព្រះវស្សានៅវត្តព្រៃយុថ្កា ព្រមទាំងចុះត្រួតពិនិត្យការស្ថាបនាផ្លូវបេតុងក្នុងឃុំចំនួន៤ខ្សែ ប្រវែង១.៤០០ម៉ែត្រ និងឧបត្ថម្ភថវិកាមួយចំនួនលើកទឹកចិត្តដល់មន្ត្រីពាក់ព័ន្ធក្នុងឃុំយុថ្កា។

❈នាថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០២៣ ឯកឧត្តម **អន ស៊ុំ** លេខាធិការគណៈកម្មការទី៤ព្រឹទ្ធសភា និងឯកឧត្តម **ឈើយ ចាន់ណា** លេខាធិការគណៈកម្មការទី៧ព្រឹទ្ធ-សភាបានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ ឆ្នាំ២០២៣ ក្រោមអធិបតីភាពឯកឧត្តម **កៃ គឹមយ៉ាន** តំណាងរាស្ត្រមណ្ឌលខេត្តបន្ទាយមានជ័យ នៅខេត្តបន្ទាយមានជ័យ។

❈ឯកឧត្តម **ឆាយ វណ្ណា** លេខាធិការគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញ៖



-ជួបសំណេះសំណាល និងសួរសុខទុក្ខក្រុមប្រឹក្សាឃុំ

ចុងជាច និងក្រុមប្រឹក្សាឃុំសេដា ព្រមទាំងឧបត្ថម្ភសារុង១ និងថវិកាមួយចំនួន នៅស្រុកដំបែរ ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២៣។



-ចូលរួមជាអធិបតីភាពក្នុងពិធីប្រឡងសូត្រគម្ពីរអាល់-គួរអាន និងចែករង្វាន់ជ័យលាភីជូនករី និងករីអះ នៅឃុំប៉ើស១ ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ នារសៀលថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២៣។

❋ឯកឧត្តម **គឹម ឆា** លេខាធិការគណៈកម្មការទី៦ ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីផ្សព្វផ្សាយអំពីលទ្ធផល នៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ ឆ្នាំ២០២៣ នៅឃុំព្រះពន្លា ស្រុកកំពង់រោទ៍ ខេត្តស្វាយរៀង នាថ្ងៃទី២ ខែកញ្ញា ឆ្នាំ ២០២៣។

-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីផ្សព្វផ្សាយអំពីលទ្ធផល នៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ ឆ្នាំ២០២៣ និងឈ្វេងយល់វឌ្ឍនភាព ក្ដីកង្វល់របស់ក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន នៅឃុំតាសួស ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង នាថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០២៣។

❋ឯកឧត្តម **ឈើយ ចាន់ណា** លេខាធិការគណៈ-កម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញ៖



-ចូលរួមក្នុងពិធីបំពាក់គ្រឿងឥស្សរិយយសការងារជូនបុគ្គលិកអប់រំ នៃមន្ទីរអប់រំ យុវជន និងកីឡា ខេត្តបន្ទាយ-មានជ័យ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា នាថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៣។



-ចូលរួមពិធីសម្ពោធអគារសិក្សា១ខ្នង មាន៦បន្ទប់ នៅសាលាបឋមសិក្សាត្រពាំងថ្ម ក្រោមអធិបតីភាពឯកឧត្តមនាយឧត្តមសេនីយ៍ **កែ គឹមយ៉ាន** នៅឃុំប៉ោយចារ ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ នាថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២៣។

❋លោកជំទាវ **មុំ សណ្ដាប់** លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាលជាមួយនឹងប្រធានសមាគមមណ្ឌលកម្សាន្តឆ្នេរខ្សាច់កោះដាច់ នៅសង្កាត់កោះដាច់ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ នាព្រឹកថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខសមាជិកក្រុម-ប្រឹក្សាសង្កាត់ផ្សារដើមថ្កូវ នៅសាលាសង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ នាថ្ងៃទី១២ ខែកញ្ញា ឆ្នាំ ២០២៣។

❋ឯកឧត្តម **ញ៉ែម សុខ** សមាជិកគណៈកម្មការទី២ ព្រឹទ្ធសភាបានអញ្ជើញ៖

-ជាអធិបតីភាពក្នុងពិធីជួបសំណេះសំណាល និងពិភាក្សាការងារជាមួយនឹងក្រុមប្រឹក្សាឃុំ ប្រធានភូមិទាំង៤ ក្នុងឃុំរកាត ក្រោមប្រធានបទ៖ **១**-ការវាយតម្លៃការងារបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ កន្លងមកនៅក្នុងឃុំ **២**-ការអនុវត្តតួនាទី ភារកិច្ចរបស់ឃុំ ពិសេសការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព និង**៣**-ស្ថានភាព នៃការដោះស្រាយទុក្ខលំបាក និងសំណូមពររបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួនដល់អ្នកចូលរួមផងដែរ នៅស្រុកភ្នំក្រវាញ ខេត្តពោធិ៍-សាត់ នាថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២៣។

-នាំយកចង្ហាន់បិណ្ឌបាត ទេយ្យទាន និងថវិកាបង្សុកូលប្រគេនព្រះពោធិវង្សាវិមល ព្រះមេគណខេត្ត និងព្រះសង្ឃ

ដែលគង់ចាំព្រះវស្សាក្នុងអារាមវត្តកែវវិជ័យ ព្រមទាំងប្រគេនថវិកាមួយចំនួនចូលរួមសម្រាប់ជាវទូក-ង និងជាវវថយន្តនាគផងដែរ នៅស្រុកកណ្ដៀង ខេត្តពោធិ៍សាត់ នាថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៣។

❈ឯកឧត្តម **លី សារី** សមាជិកគណៈកម្មការទី៣ព្រឹទ្ធ-សភាបានអញ្ជើញៈ

-ចូលរួមគោរពវិញ្ញាណក្ខន្ធសពប្រជាពលរដ្ឋ នៅភូមិត្រពាំងរពៅ សង្កាត់ព្រែកត្នោត ក្រុងបូកគោ ខេត្តកំពត នារសៀលថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋ ព្រមទាំងចូលរួមពិសាអាហារសាមគ្គីជាមួយនឹងពួកគាត់ នៅក្នុងភូមិម៉ាក់ប្រាង្គ ឃុំកំពង់ក្រែង ស្រុកទឹកឈូ ខេត្តកំពត នារសៀលថ្ងៃទី២៨ និងថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៣។

-ចូលរួមពិធីគោរពវិញ្ញាណក្ខន្ធសពប្រជាពលរដ្ឋ ព្រម-ទាំងឧបត្ថម្ភថវិកាមួយចំនួន នៅភូមិត្រើយកោះ សង្កាត់ត្រើយកោះ ខេត្តកំពត នាព្រឹកថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋ នៅភូមិព្រៃថ្នង ឃុំព្រៃថ្នង ស្រុកទឹកឈូ ខេត្តកំពត នាព្រឹកថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២៣។

-ចូលរួមគោរពវិញ្ញាណក្ខន្ធសពប្រជាពលរដ្ឋ នៅភូមិកំពង់កណ្ដាល ឃុំជុំគ្រៀល ស្រុកទឹកឈូ ខេត្តកំពត នាព្រឹកថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខសិស្សានុសិស្ស ដែលកំពុងស្នាក់នៅមណ្ឌលសិក្សាឡូលហ៊ីឌើយ៉ាស ព្រម-ទាំងបានឧបត្ថម្ភថវិកាមួយចំនួនជូនលោកគ្រូសម្រាប់ផ្គត់ផ្គង់សិស្សានុសិស្សនៅភូមិត្រពាំងសង្កែ ឃុំត្រពាំងសង្កែ ស្រុកទឹកឈូ ខេត្តកំពត នារសៀលថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២៣។

-ចូលរួមពិធីសំណេះសំណាល និងសួរសុខទុក្ខប្រជា-ពលរដ្ឋក្រោមអធិបតីភាពឯកឧត្តម **ម៉ែន ស៊ីម៉ន** ប្រធានគណៈកម្មការទី១០រដ្ឋសភា នៅសាលសន្និសីទបូកគោ ខេត្តកំពត នាព្រឹកថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២៣។

❈នាព្រឹកថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៣ ឯកឧត្តម **សត ណាឌី** សមាជិកគណៈកម្មការទី៤ព្រឹទ្ធសភា ឯកឧត្តម **សួន លន់** សមាជិកគណៈកម្មការទី១០ព្រឹទ្ធសភា និងលោកជំទាវ **ឯម ផលាមុនី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំបូកសរុបដកបទ-ពិសោធន៍សកម្មភាព និងលទ្ធផលការងារបោះឆ្នោតជ្រើស-តាំងតំណាងរាស្ត្រនីតិកាលទី៧ ក្រោមអធិបតីភាពដ៏ខ្ពង់-ខ្ពស់សម្ដេចពិជ័យសេនា **ទៀ បាញ់** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៅខេត្តសៀមរាប។

❈នាថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២៣ ឯកឧត្តម **ម្លូច ម៉ុយ** សមាជិកគណៈកម្មការទី៤ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ នៅភូមិកិត្តុង ឃុំវាវែងក្រោម ស្រុកតាវែង ខេត្តរតនគិរី ។

❈នាថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២៣ លោកជំទាវ **ឃួន ឃុនឌី** សមាជិកាគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញចូលរួមកិច្ចប្រជុំផ្សព្វផ្សាយសេចក្ដីសម្រេចស្ដីពី ផែនការរួមឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី៥ ឆ្នាំ២០២៤ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត **ជា ចាន់តូ** នៅសាលាខេត្តកំពង់ធំ។

❈ឯកឧត្តម **អ៊ុក គង់** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញៈ

-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីផ្សព្វផ្សាយអំពីលទ្ធផល នៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ ឆ្នាំ២០២៣ និងឈ្វេងយល់វឌ្ឍនភាព ក្ដីកង្វល់របស់ក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន នៅសាលាខេត្តបាត់ដំបង ខេត្តបាត់ដំបង នាថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលជាមួយនឹងមន្ត្រីបរិស្ថាន និងមន្ត្រីព្រៃឈើ អំពីការងារកសិកម្ម បរិស្ថាន នៅក្រុងបាត់ដំបង ខេត្តបាត់ដំបង នាថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២៣។

❈នាថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២៣ ឯកឧត្តម **ស្រី បេន** សមាជិកគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាលប្រជាពលរដ្ឋក្នុងភូមិវែង ឃុំសឹង្ហ ស្រុកសំរោង ខេត្តតាកែវ។

❈ឯកឧត្តម **ឡៅ ឆន** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញៈ

-ចូលរួមប្រជុំជាមួយក្រុមប្រឹក្សាក្រុង ស្រុកទាំង៥ ក្រុម-ប្រឹក្សាឃុំ សង្កាត់ទាំង២៥ ខេត្តឧត្តរមានជ័យ ក្រោមអធិបតី-ភាពឯកឧត្តមកិត្តិសង្គហបណ្ឌិត **គន់ គីម** ទេសរដ្ឋមន្ត្រី ដើម្បីរៀបចំ និងចងក្រងឯកសារលទ្ធផលបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ និងរបាយការណ៍ស្ដីពីលទ្ធផលការងារ៩ខែ និងទិសដៅការងារសម្រាប់ខែតុលា ឆ្នាំ២០២៣ នាថ្ងៃទី២៦ ខែសីហា និងថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២៣។

-នាំយកនូវទេយ្យទានជាគ្រឿងឧបភោគ បរិភោគ និង



ថវិកាមួយចំនួន ទៅប្រគេនព្រះបាឡាដសង្ឃខេត្ត ព្រះសង្ឃគង់ចាំព្រះវស្សាអស់កាលត្រីមាស និងជួយផ្គត់ផ្គង់ចង្ហាន់ប្រចាំថ្ងៃ ដល់ព្រះសង្ឃដែលកំពុងគង់នៅបន្តការសិក្សាក្នុងទីអារាម ចំនួន៨០អង្គ នៅវត្តព្រះព្រហ្មរតន៍ សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប នាថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៣។



-ចុះសួរសុខទុក្ខ និងឧបត្ថម្ភថវិកាមួយចំនួនជូនលោក **ជា ផល** មន្ត្រីមន្ទីរសុខាភិបាលខេត្តសៀមរាប មានជំងឺលើសសម្ពាធឈាម កំពុងសម្រាកព្យាបាលជំងឺ នៅមន្ទីរ-ពេទ្យកាល់ម៉ែត្រ រាជធានីភ្នំពេញ នាថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២៣។

❋ឯកឧត្តម **អ៊ឹង លាងហ៊ួ** សមាជិកគណៈកម្មការទី៧ ព្រឹទ្ធសភាបានអញ្ជើញ៖



-ដឹកនាំមន្ត្រីមូលដ្ឋានឃុំព្រៃគ្រី នាំយកនូវគ្រឿងឧបភោគបរិភោគ បច្ច័យ៤ ទៅប្រគេនព្រះសង្ឃគង់ចាំព្រះវស្សាអស់កាលត្រីមាស ចំនួន៣វត្ត និងរៀបចំអាហារសាមគ្គីជូនប្រជាពលរដ្ឋ ចំនួន៥ភូមិ នៅឃុំព្រៃគ្រី ស្រុកជលគិរី ខេត្តកំពង់ឆ្នាំង នាថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២៣។



-ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាឃុំ ស្មៀនឃុំ ជំនួយការស្មៀន ប៉ុស្តិ៍រដ្ឋបាលឃុំ ប្រធានភូមិ ឃុំព្រៃគ្រី និងឃុំកំពង់អុស ដើម្បីឈ្វេងយល់ពីសភាពការណ៍ទូទៅរបស់ឃុំ ផែនការបន្ត និងការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ នៅស្រុកជលគិរី ខេត្តកំពង់ឆ្នាំងនាថ្ងៃទី៩ និងថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២៣។

❋ឯកឧត្តម **ទេព យុទ្ធី** សមាជិកគណៈកម្មការទី៨ ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋ ដែលទទួលរងគ្រោះអគ្គិភ័យឆេះលំនៅដ្ឋាន និងឃ្លាំងស្តុកទំនិញ នៅភូមិរនេស ឃុំពងទឹក ស្រុកដំណាក់ចង្អើរ ខេត្តកែប នាថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២៣។

-ចូលរួមគោរពវិញ្ញាណកន្ធសពលោក **គង់ លាត** សមាជិកក្រុមប្រឹក្សាស្រុកដំណាក់ចង្អើរ នៅគេហដ្ឋានសព នៅភូមិអូរក្រសារ សង្កាត់អូរក្រសារ ក្រុងកែប ខេត្តកែប នាថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០២៣។

❋លោកជំទាវ **ឯម ផលាមុនី** សមាជិកាគណៈកម្ម-ការទី១០ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាល និងសួរសុខទុក្ខលោកយាយ **អ៊ុំកែវ សារ៉ាត** អាយុ៧៦ឆ្នាំ និងអ្នកគ្រូ **សា យ័ន្ត** អាយុ៧២ឆ្នាំ ដែលកំពុងសម្រាកព្យាបាលជំងឺនៅគេហដ្ឋាន ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួន នៅសង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប នាព្រឹកថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៣។

-នាំយកបច្ច័យមួយចំនួនទៅវេរប្រគេនព្រះសង្ឃគង់នៅវត្តចំនួន៣វត្តគឺ៖ វត្តព្រះឥន្ទកោសីយ៍ វត្តព្រះឥន្ទកោសា និងវត្តអង្គរខាងជើង នៅក្រុងសៀមរាប ខេត្តសៀមរាប នាព្រឹកថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៣៕

# សមាជិក សមាជិកាព្រឹទ្ធសភាចូលរួមក្នុងពិធីផ្សេងៗ

❈ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមពិធីបុណ្យសពឧបាសិកា **ឡុង ឡាងអេង** ដែលបានទទួលមរណភាពដោយរោគាពាធ នៅសង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ នាព្រឹកថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២៣។

-ទទួលជួបក្រុមវិនិយោគជនជាតិជប៉ុន ដែលមានបំណងចង់បណ្តាក់ទុនវិនិយោគវិស័យកសិ-ឧស្សាហកម្ម នៅព្រះរាជាណាចក្រកម្ពុជា នៅភោជនីយដ្ឋាន Dinak រាជធានីភ្នំពេញ នារសៀលថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២៣។

-ចូលរួមប្រជុំសភាពាណិជ្ជកម្ម ក្នុងនាមជាសហប្រធានក្រុមការងារ (ក/ទី១) ផ្នែកកសិកម្ម កសិឧស្សាហកម្ម នៃវេទិការាជរដ្ឋាភិបាល និងផ្នែកឯកជន ដើម្បីត្រៀមចូលរួមវេទិការាជរដ្ឋាភិបាល និងផ្នែកឯកជន លើកទី១៩ ដែលនឹងប្រព្រឹត្តទៅនៅខែវិច្ឆិកាខាងមុខ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសភាពាណិជ្ជកម្មកម្ពុជា បន្ទប់ប្រជុំជាន់ទី១ នាព្រឹកថ្ងៃពុធ ទី១៣ ខែកញ្ញា ឆ្នាំ២០២៣។

-ចូលរួមកម្មវិធីបើកកិច្ចប្រជុំថ្នាក់ដឹកនាំលើកទី២០សមាគមជាតិកាកបាទក្រហម និងអឌ្ឍចន្ទក្រហម ភូមិភាគអាស៊ីអាគ្នេយ៍ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា នៅសណ្ឋាគារសុខា រាជធានីភ្នំពេញ នាថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២៣។

-ចូលរួមកម្មវិធីលៀងសាយភោជន៍អបអរលទ្ធផលកិច្ចប្រជុំថ្នាក់ដឹកនាំលើកទី២០ និងវេទិកាយុវជនលើកទី២ នៃសមាគមជាតិកាកបាទក្រហម និងអឌ្ឍចន្ទក្រហម ភូមិភាគអាស៊ីអាគ្នេយ៍ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា នៅមជ្ឈមណ្ឌលសន្និបាតអន្តរជាតិជ្រោយចង្វារ អូ.ស៊ី.អាយ.ស៊ី នាថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២៣។

❈ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា និងឯកឧត្តម **ទឹម ផន** លេខាធិការគណៈកម្មការទី៩ព្រឹទ្ធសភាបានអញ្ជើញចូលរួមពិធីអបអរសាទរ "ការចុះបញ្ជីរមណីយដ្ឋានប្រាសាទកោះកេរ" ក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ដែលប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅពហុកីឡដ្ឋានជាតិអូឡាំពិក នារសៀលថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣។

❈នាថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៣ ឯកឧត្តម **សុខ ឥសាន** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីអបអរសាទខួបលើកទី៧៨ឆ្នាំ នៃទិវាបុណ្យឯករាជ្យជាតិ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម នៅសណ្ឋាគារសូហ្វីតែល រាជធានីភ្នំពេញ។

❈ឯកឧត្តម **សុខ ឥសាន** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា និងឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមជាកិត្តិយសក្នុងពិធីខួបអនុស្សាវរីយ៍លើកទី៣៣ ថ្ងៃប្រកាសបង្កើតកងវរសេនាតូចលេខ២៤៦ និងខួបអនុស្សាវរីយ៍គម្រប់ឆ្នាំលើកទី១៤ ថ្ងៃប្រកាសបង្កើតបញ្ជាការដ្ឋានអង្គរក្ស ក្រោមអធិបតីភាពឯកឧត្តមសន្តិបណ្ឌិត **នេត សាវឿន** ឧបនាយករដ្ឋមន្ត្រី នៅទីបញ្ជាការ បញ្ជាការដ្ឋានអង្គរក្ស ទួលក្រសាំង ក្រុងតាខ្មៅ ខេត្តកណ្តាល នាព្រឹកថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០២៣។



-ចូលរួមជាកិត្តិយសក្នុងពិធីអបអរខួបលើកទី៧០ នៃទំនាក់ទំនងមិត្តភាពជប៉ុន-កម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចមហារដ្ឋសភាធិការធិបតី **ឃួន សុដារី** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម UENO Atsushi ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា នៅអគារ CJCC Angkor Kizuna Hall សាកលវិទ្យាល័យភូមិន្ទភ្នំពេញ នាថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៣។



❈នាថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២៣ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ម៉ុម ជឹមហ៊ុយ** ប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា ឯកឧត្តម **ឡៅ ឆន** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភា និងឯកឧត្តម **អ៊ឹង លាងហ៊ួ** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញដាក់កូរោនផ្កាគោរពវិញ្ញាណក្ខន្ធសពឧបាសិកា **ខែក គឹមលាង** ដែលបានទទួលមរណភាព ដោយរោគាពាធក្នុងជន្មាយុ ៦៤ឆ្នាំ នៅផ្ទះលេខ AZ2 ផ្លូវ១៩៨៦ ភូមិភ្នំពេញថ្មី សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

❈លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមពិធីសំណេះសំណាលកម្មករ និយោជិត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅភូមិកោះគរ សង្កាត់រកាខ្ពស់ ក្រុងតាខ្មៅ ខេត្តកណ្ដាល នាថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២៣។

-ចូលរួមពិធីសំណេះសំណាលកម្មករ និយោជិត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចមហាបវរធិបតី **ហ៊ុន ម៉ាណែត**



នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅភូមិរំដួល ឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២៣។

❈នាព្រឹកថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៣ លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា និងឯកឧត្តម **ទេព យុទ្ធី** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញជាអធិបតីក្នុងពិធីបើក និងបិទកិច្ចសន្ទនាកម្រិតប្រទេស ស្ដីពីកិច្ចប្រជុំកម្រិតខ្ពស់របស់អង្គការសហប្រជាជាតិ ស្ដីពីជំងឺរបេង ឆ្នាំ២០២៣ ដោយមានការចូលរួមពីថ្នាក់ដឹកនាំតាមក្រសួងស្ថាប័នពាក់ព័ន្ធនានា តំណាងអង្គការ សុខភាពពិភពលោក (WHO), អង្គការ KHANA, អង្គការ Stop TB Partnership ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់អភិវឌ្ឍន៍អន្តរជាតិ (USAID) នៅសណ្ឋាគារសាន់វ៉េ រាជធានីភ្នំពេញ។

❈នារាត្រីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា បានអញ្ជើញចូលរួមរំលែកទុក្ខក្រុមគ្រួសារសពឯកឧត្តមបណ្ឌិត **សំ សិរីរតន៍** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ដែលបានទទួលមរណភាពក្នុងជន្មាយុ៧០ឆ្នាំ ដោយរោគាពាធ ព្រមទាំងនាំយកបច្ច័យមួយចំនួនចូលបុណ្យ នៅគេហដ្ឋានផ្ទះលេខ១០ ផ្លូវលុច្សារី ក្នុងបុរីហាយធិចលុច្សារី ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។

❈នាព្រឹកថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៣ លោកជំទាវ **មុំ សណ្ដាប់** លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញចូលរួមពិធីសំណេះសំណាលកម្មករ និយោជិត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅជាប់វត្តព្រៃស្ពឺ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

# អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែសីហា និងកំណត់ទិសដៅការងារខែកញ្ញា ឆ្នាំ២០២៣




*ឯកឧត្តម ឡោក ឆាយ ឯកឧត្តម អ៊ុំ សារឹទ្ធ ឯកឧត្តម លឹម ប៊ុនហុក*

នាព្រឹកថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៣ អគ្គលេខាធិការ-ដ្ឋានព្រឹទ្ធសភាបានប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែសីហា និងលើកទិសដៅការងារសម្រាប់ខែកញ្ញា ឆ្នាំ២០២៣ ក្រោមអធិបតីភាពរបស់ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខា-ធិការព្រឹទ្ធសភា នៅសាលសិក្ខាសាលាបណ្ណាល័យព្រឹទ្ធសភា ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចាប់ពីអនុប្រធាននាយក-ដ្ឋានឡើង។

មានប្រសាសន៍ក្នុងឱកាសនោះ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានថ្លែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះអង្គភាពពាក់ព័ន្ធទាំងអស់ ដែលបានផ្តល់សេវាយ៉ាងល្អប្រសើរ និងឆ្លើយតបបានតាមសំណូមពររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការបំពេញតួនាទីភារកិច្ចរបស់គាត់។ ក្នុងបរិបទ នៃដំណើរឆ្ពោះទៅការបញ្ចប់នីតិកាលទី៤ និងការចាប់ផ្តើមនីតិកាលទី៥ របស់ព្រឹទ្ធសភាឱ្យសម្រេចបានតាមប្រតិទិនការងារ និងធានាបានភាពរលូន។ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានកសាងឯកសារគោលសំខាន់ៗ និងផែនការសកម្មភាពការងារ ព្រមជាមួយនឹងការបំពាក់សម្ភារៈ ការកសាង ជួសជុល ថែទាំ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្តនានាសម្រាប់ព្រឹទ្ធសភា នីតិកាលទី៥។ ជាមួយគ្នានេះ អគ្គលេខាធិការ-ដ្ឋានព្រឹទ្ធសភាបានកសាងផែនការយុទ្ធសាស្ត្រ ៣ឆ្នាំរំកិល ២០២៤-២០២៦ និងបានកំពុងដំណើរការនីតិវិធីគម្រោងថវិកាសម្រាប់ឆ្នាំ២០២៤ របស់ព្រឹទ្ធសភា។

សម្រាប់ខែកញ្ញាខាងមុខនេះ ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភាបានណែនាំដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការ នៃអគ្គ-លេខាធិការដ្ឋានព្រឹទ្ធសភា ត្រៀមសព្វសារពើ សម្រាប់ការងារខាងមុខ គឺជារឿងអាទិភាព ដែលគ្រប់ថ្នាក់ គ្រប់ផ្នែក គ្រប់វិស័យ ត្រូវតែខិតខំជាអតិបរមា ដើម្បីឆ្ពោះទៅរកការរៀបចំលក្ខណសម្បត្តិសព្វយ៉ាង ទាំងទីកន្លែងធ្វើការ ធនធានសម្ភារៈ បរិក្ខារ បច្ចេកទេស បច្ចេកវិទ្យា និងហិរញ្ញវត្ថុមានគ្រប់គ្រាន់ក្នុងដៃ និងម្ចាស់ការលើការរៀបចំបានទាន់ពេលវេលាដូចការគ្រោងទុក។ ទន្ទឹមគ្នានោះ ពេលវេលាក៏កាន់តែលឿនទៅមុខ ដើម្បីសម្រេចផែនការយុទ្ធសាស្ត្រព្រឹទ្ធសភាឌីជីថល និងបៃតង ២០២៤-២០៣០ ក្នុងបរិបទនៃព្រឹទ្ធសភា នីតិកាលទី៥។

ឯកឧត្តមបានបញ្ជាក់បន្ថែមថា ក្រៅពីនេះការវិនិយោគបន្ថែមថ្មីៗ ដើម្បីបំពេញតម្រូវការមូលដ្ឋានសម្ភារៈ បច្ចេក-ទេស បច្ចេកវិទ្យា បរិស្ថាន និងទីកន្លែងធ្វើការសម្រាប់នីតិកាលថ្មី គឺជាកិច្ចការពិសេស បន្ទាន់ និងចាំបាច់បំផុត។ ជាមួយគ្នានេះ ថ្នាក់ដឹកនាំ មន្ត្រីរាជការទាំងអស់ត្រូវបន្តយកចិត្តទុកដាក់ផ្តល់សេវាជូនសមាជិក សមាជិកាព្រឹទ្ធ-សភា លើមុខងារទាំង៥របស់ព្រឹទ្ធសភាឱ្យគ្រប់ជ្រុងជ្រោយប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល កាន់តែល្អប្រសើរឡើងបន្ថែមទៀត។

(អត្ថបទ និងរូបភាព៖ លោក វង់ សុជាតិ)



*ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចូលរួមក្នុងកិច្ចប្រជុំបូកសរុបប្រចាំខែសីហា និងលើកទិសដៅខែកញ្ញា ឆ្នាំ២០២៣*

# ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភាអញ្ជើញចូលរួម មហាសន្និបាតសមាគមអគ្គលេខាធិការសភាប្រើភាសាបារាំង



*ឯកឧត្តម អ៊ុំ សារិទ្ធ ថតរូបអនុស្សាវរីយ៍ជាមួយអគ្គលេខាធិការសភានានា*

កាលពីថ្ងៃទី៨ ដល់ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២៣ ឯកឧត្តម **អ៊ុំ សារិទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា និងជាសមាជិក នៃសមាគមអគ្គលេខាធិការសភាប្រើភាសាបារាំង បានអញ្ជើញចូលរួមមហាសន្និបាត នៃសមាគមអគ្គលេខាធិការសភាប្រើភាសាបារាំង នៅសភាសហព័ន្ធវ៉ាល់ឡូនីព្រុចសែល ប្រទេសប៊ែលហ្សិក។

មហាសន្និបាតប្រព្រឹត្តទៅក្រោមអធិបតីភាពលោក Siegfried Peters ប្រធានសមាគមអគ្គលេខាធិការសភាប្រើភាសាបារាំង និងជាអគ្គលេខាធិការរដ្ឋសភា នៃខេត្តកេប៊ិច ប្រទេសកាណាដា (Québec-Canada) ដោយមានការអញ្ជើញចូលរួមចំនួន២១ ប្រទេស (៤៥រូប) មកពីទ្វីបអឺរ៉ុប ទ្វីបអាមេរិក ទ្វីបអាហ្វ្រិក និងទ្វីបអាស៊ី។

អង្គមហាសន្និបាតបានពិនិត្យ និងអនុម័តដោយឯកភាពទាំងស្រុងលើរបៀបវារៈដូចខាងក្រោម៖

១-កំណត់ហេតុ នៃមហាសន្និបាតដែលបានប្រព្រឹត្តទៅនៅទីក្រុងរ៉ាបាត (Rabat) ប្រទេសម៉ារ៉ុក កាលពីថ្ងៃទី២ និងថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០២៣

២-សមាសភាព នៃគណៈកម្មាធិការអចិន្ត្រៃយ៍សមាគម

៣-របាយការណ៍សកម្មភាពឆ្នាំ២០២២-២០២៣

៤-ស្ថានភាពហិរញ្ញវត្ថុរបស់សមាគម

៥-ទំនាក់ទំនងជាមួយលេខាធិការដ្ឋានអង្គការសភាប្រើភាសាបារាំង

៦-ការផ្តល់អាហារូបករណ៍ Marie Joséphine Diallo សម្រាប់មន្ត្រីអគ្គលេខាធិការដ្ឋានសភានៅក្នុងលំហហ្វ្រង់កូហ្វូនី (ជំនាន់២០២២-២០២៣/២០២៣-២០២៤)

-គម្រោងប្រចាំឆ្នាំសម្រាប់ការរៀបចំវគ្គបណ្តុះបណ្តាលពីចម្ងាយដល់មន្ត្រីអគ្គលេខាធិការដ្ឋានសភានានា

-គម្រោងបន្ត នៃការជួសជុលឡើងវិញនូវគេហទំព័ររបស់សមាគម

-កំណត់កាលបរិច្ឆេទ ទីកន្លែង និងប្រធានបទ សម្រាប់កិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងមហាសន្និបាតនៅលើកក្រោយ (ខែកក្កដា ឆ្នាំ២០២៤-រដ្ឋសភាកាណាដា)

-បញ្ហាផ្សេងៗ។

បន្ទាប់មកមហាសន្និបាតបានពិភាក្សា ផ្លាស់ប្តូរមតិ និងបទពិសោធន៍ថ្មីៗជុំវិញប្រធានបទចំនួនបី រួមមាន៖ **១**-ការជ្រើសរើសមន្ត្រីមកបំពេញការងារនៅក្នុងស្ថាប័នសភា៖ តើសភាផ្អែកលើមូលដ្ឋានអ្វីខ្លះ?។ **២**-កម្មវិធីកិច្ចការសភាបន្តទៅថ្ងៃអនាគត តើសភានីមួយៗត្រូវមានយុទ្ធសាស្ត្រ រៀបចំខ្លួនអ្វីខ្លះក្នុងករណីមានវិបត្តិធ្ងន់ធ្ងរ?។ **៣**-តួនាទីរបស់មន្ត្រីបម្រើការងារនៅក្នុងលេខាធិការដ្ឋានគណៈកម្មការ តើមន្ត្រីត្រូវជួយអ្វីខ្លះដល់សមាជិកសមាជិកាសភា?។

ក្រៅពីចូលរួមមហាសន្និបាត ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញជួបសន្ទនាការងារជាមួយនឹងដៃគូការងារមានដូចជា៖ អគ្គលេខាធិការព្រឹទ្ធសភា និងរដ្ឋសភាបារាំង អគ្គលេខាធិការសភាសហព័ន្ធវ៉ាល់ឡូនីព្រុចសែល អគ្គលេខាធិការរដ្ឋសភាកាណាដា អគ្គលេខាធិការរដ្ឋសភាកេប៊ិច និងអគ្គលេខាធិការសភាម៉ារ៉ុក ព្រមទាំងចូលរួមប្រជុំគណៈកម្មការប្រតិបត្តិ នៃវិទ្យាស្ថានសភាអាស៊ី ដើម្បីកំណត់ផែនការសកម្មភាពការងារចុងឆ្នាំ២០២៣ និងឆ្នាំ២០២៤។

តាមរយៈការចូលរួមមហាសន្និបាតសមាគមអគ្គលេខាធិការសភា បាននាំមកនូវការអនុវត្តមូលដ្ឋានគ្រឹះសម្រាប់ការទូតសភាក្នុងរង្វង់សមាគមសភាប្រើភាសាបារាំង ព្រមទាំងបទពិសោធន៍ជាគ្រឹះរបស់អគ្គលេខាធិការដ្ឋានសភានានា ដើម្បីចែករំលែកនូវយុទ្ធសាស្ត្រ ផែនការ កម្មវិធី វិធានការ និងទស្សនៈសំខាន់ៗជាប្រយោជន៍សម្រាប់ការគ្រប់គ្រងសភាជាទូទៅនាយុគសម័យបច្ចុប្បន្ន ដែលកំពុងមានការប្រែប្រួល មិនទៀងទាត់ដែលនាំមកនូវឧបសគ្គ និងការលំបាកថ្មីៗដល់សភានានាលើពិភពលោកគ្រប់ពេលវេលា។ រដ្ឋបាលសភាត្រូវត្រៀមខ្លួនដោះស្រាយវិបត្តិតូចធំ និងការគាំទ្រខាងជំនាញ និងនីតិវិធីមុតស្រួច រឹងមាំ និងទាន់ពេលវេលាដល់សភា។ ថ្នាក់ដឹកនាំ និងសមាជិកសភា ដែលជាទូទៅតែងប្រឆាំង និងទំនាស់គ្នាដោយសារជំហរនយោបាយតាមគណបក្សរៀងៗខ្លួន ព្រមទាំងភាពចៃដន្យ និងតម្រូវការប្រែប្រួលមិនទៀងទាត់ នៃយុគសម័យដែលបង្កើតនូវបញ្ហា និងវិបត្តិថ្មីៗដែលកើតឡើង។ តម្រូវការរបស់ប្រជាជន សង្គមជាតិ និងប្រទេស តែងតែប្រែប្រួលគ្រប់ពេលវេលាពីដំណាក់កាលមួយទៅដំណាក់កាលមួយទៀត ទាំងបរិមាណនិងគុណភាព។ មុខងារនីតិកម្ម មុខងារតំណាង និងមុខងារតាមដានការអនុវត្តច្បាប់តែងបត់បែនប្រែប្រួលតាមតម្រូវការ នៃពេលវេលានីមួយៗ។

(អត្ថបទ៖ អគ្គលេខាធិការ រូបភាព៖ នុត សច្ចៈ)

# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ

❈នាព្រឹកថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២៣ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការលទ្ធកម្ម នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដើម្បីពិនិត្យលើរបាយការណ៍ការអនុវត្តកិច្ច-ការលទ្ធកម្មឆ្នាំ២០២៣ និងពិនិត្យសម្រេចលើផែនការលទ្ធកម្មឆ្នាំ២០២៤ នៅសាលប្រជុំពិសេសជាន់ក្រោម វិមានព្រឹទ្ធសភា។



❈នារសៀលថ្ងៃទី៣០ ខែសីហា ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៣ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញជាអធិបតីភាពក្នុងកិច្ចប្រជុំពិនិត្យ និងពិភាក្សា ដើម្បីត្រៀមលក្ខណៈរៀបចំបើកសម័យប្រជុំដំបូងព្រឹទ្ធសភា នីតិកាលទី៥ នៅសាលប្រជុំពិសេសជាន់ក្រោម វិមានព្រឹទ្ធសភា ដោយមានការអញ្ជើញចូលរួមពីអគ្គលេខាធិ-ការរងព្រឹទ្ធសភា ថ្នាក់ដឹកនាំអគ្គនាយកដ្ឋានទាំង៥ អគ្គា-ធិការ និងថ្នាក់ដឹកនាំអង្គភាពពាក់ព័ន្ធ។



❈នារសៀលថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៣ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានទទួលជួបពិភាក្សាការងារជាមួយនឹងឯកឧត្តម **ឡេង ប៉េងឡុង** អគ្គលេខា-ធិការរដ្ឋសភា ដើម្បីពិនិត្យពិភាក្សាទាក់ទងនឹងការងារសហប្រតិបត្តិការអន្តរជាតិរបស់សភាទាំងពីរ (ព្រឹទ្ធសភា រដ្ឋសភា) នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។



❈នាព្រឹកថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២៣ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មការបូកសរុបលទ្ធផលការងារព្រឹទ្ធសភា នីតិកាលទី៤ (២០១៨-២០២៤) ដើម្បីពិនិត្យអំពីវឌ្ឍនភាពការងារបូកសរុបលទ្ធផលការងាររបស់ព្រឹទ្ធសភា នីតិកាលទី៤ នៅសាលប្រជុំពិសេសជាន់ក្រោម វិមានព្រឹទ្ធសភា។



# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ

❈នាព្រឹកថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២៣ ឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការស្តីទីព្រឹទ្ធសភា បានអញ្ជើញជាអធិបតីភាពក្នុងពិធីបិទវគ្គបណ្តុះបណ្តាលស្តីពី ជំនាញអភិវឌ្ឍន៍ខ្លួន (Self-Development) ឧទ្ទេសនាមដោយលោក Subramaniam ADinaraian អនុប្រធានរាជបណ្ឌិត្យសភាអប់រំកែប្រែកាយសម្បទា និងជាអ្នកសម្របសម្រួលគម្រោងកិច្ចសហប្រតិបត្តិការបច្ចេកទេសម៉ាឡេស៊ី នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។



❈នារសៀលថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៣ ឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មការពិសេស ដើម្បីពិនិត្យ និងសិក្សាកែសម្រួលគោលការណ៍ណែនាំរួម ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសំខាន់ៗ សម្រាប់នីតិកាលទី៥ នៃព្រឹទ្ធសភា និងពិនិត្យពិភាក្សាការងារផ្សេងៗ នៅសាលប្រជុំពិសេសខាងក្រោម វិមានព្រឹទ្ធសភា។



❈នាព្រឹកថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២៣ ឯកឧត្តម **ទេព ចាន់អុនឧុធីរក្ស** អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ បានអញ្ជើញដឹកនាំកិច្ចប្រជុំក្រុមការងារសិក្សាស្រាវជ្រាវស្តីពី គោលការណ៍ គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ពាក់ព័ន្ធនឹងផលប្រយោជន៍មន្ត្រីរាជការ ដើម្បីពិនិត្យសិក្សាលើសេចក្តីព្រាងសេចក្តីសម្រេចស្តីពី ការផ្តល់ប្រាក់ឧបត្ថម្ភជូនមន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យាជាស្ត្រី សម្រាប់ការពិនិត្យផ្ទៃពោះមុនសម្រាល និងសម្រាប់ការយកកូនទៅទទួលថ្នាំបង្ការរហូតដល់អាយុក្រោម២ឆ្នាំ នៅសាលប្រជុំអគារក្រហមស្លាបខាងកើត វិមានព្រឹទ្ធសភា។



❈នារសៀលថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២៣ លោកជំទាវ **រត្ន ឆវីលក្ខណ៍** អគ្គាធិការ នៃអគ្គាធិការដ្ឋានព្រឹទ្ធសភា បានអញ្ជើញធ្វើបទបង្ហាញស្តីពី រចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់អគ្គាធិការដ្ឋាន ជូនដល់មន្ត្រីរាជការដែលជាសិក្ខាកាមចូលរៀនវគ្គបណ្តុះបណ្តាលស្តីពី កិច្ចការសភា (ជំហានទី៨) នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។



## សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ

❈នាព្រឹកថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២៣ ឯកឧត្តម **កែវ ចាន់ណា** អគ្គនាយក នៃអគ្គនាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈ បានអញ្ជើញធ្វើបទបង្ហាញស្ដីពីរចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់អគ្គនាយកដ្ឋានព័ត៌មាន និងទំនាក់នងសាធារណៈ ជូនដល់មន្ត្រីរាជការដែលជាសិក្ខាកាមចូលរៀនវគ្គបណ្ដុះបណ្ដាលស្ដីពី កិច្ចការសភា (ជំហានទី៨) នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។



❈ចាប់ពីថ្ងៃទី១១ ដល់ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៣ លោកជំទាវ **សួន ពុធថាវី** អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ បានអញ្ជើញចូលរួមសិក្ខាសាលាសម្រាប់មន្ត្រីសភាប្រើភាសាបារាំង នៅសភាសហព័ន្ធវ៉ាឡូនីប្រ៊ុចសែល នៃព្រះរាជាណាចក្របែលហ្ស៊ិក។



❈នារសៀលថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៣ ឯកឧត្តម **សោម សាវុធ** អគ្គនាយករង នៃអគ្គនាយកដ្ឋានពិធីការ និងទំនាក់ទំនងអន្តរជាតិ បានអញ្ជើញធ្វើបទបង្ហាញស្ដីពីរចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់អគ្គនាយកដ្ឋានពិធីការ និងទំនាក់នងអន្តរជាតិ ជូនដល់មន្ត្រីរាជការដែលជាសិក្ខាកាមចូលរៀនវគ្គបណ្ដុះបណ្ដាលស្ដីពី កិច្ចការសភា (ជំហានទី៨) នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។



❈នាថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៣ លោកជំទាវ **សាយ ចាន់ណាក់** នាយិការងខុទ្ទកាល័យសម្ដេចប្រធានព្រឹទ្ធសភា បានអញ្ជើញនាំយកកូរោនផ្កា និងបច្ច័យរបស់សម្ដេចប្រធានព្រឹទ្ធសភា និងលោកជំទាវ ចូលរួមរំលែកទុក្ខសពម្ដាយលោកស្រី **ឌី សុខហេង** ចៅសង្កាត់ព្រៃវែង ខណ្ឌដង្កោ រាជធានីភ្នំពេញ៕





ព្រឹទ្ធសភា នីតិកាលទី ៤
សម័យប្រជុំវិសាមញ្ញ